# អនុសញ្ញាទីក្រុងប៉ារីស
# ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម
# ២០ មីនា ១៨៨៣

ដែលបានធ្វើការកែប្រែ
នៅទីក្រុង ប្រុយសែល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩០០
នៅទីក្រុង វ៉ាស៊ីនតោន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩១១
នៅទីក្រុង ឡាអេ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩២៥
នៅទីក្រុង ឡុង ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៣៤
នៅទីក្រុង លីស្បោន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៥៨
និងនៅទីក្រុង ស្តុកហូម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧
ហើយបានធ្វើវិសោធនកម្ម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៩

# មាតិកា*


| | |
|---|---|
| មាត្រា១: | ការបង្កើតសហភាព វិសាលភាពនៃកម្មសិទ្ធិឧស្សាហកម្ម |
| មាត្រា២: | ប្រព្រឹត្តិកម្មជាតិចំពោះពលរដ្ឋនៃប្រទេសជាសមាជិកសហភាព |
| មាត្រា៣: | ប្រព្រឹត្តិកម្មដូចគ្នាចំពោះប្រភេទបុគ្គលមួយចំនួនដូចពលរដ្ឋនៃប្រទេសក្នុងសហភាព |
| មាត្រា៤: | (ក) ដល់ (ឈ) : ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ម៉ាក វិញ្ញាបនបត្រតក្កករៈ សិទ្ធិអាទិភាព (ឆ) ប្រកាសនីយបត្រតក្កកម្មៈ ការបំបែកសំណុំលិខិតស្នើសុំ |
| មាត្រា៤ ស្ទួន: | ប្រកាសនីយបត្រតក្កកម្មៈ ឯករាជ្យនៃប្រកាសនីយបត្រតក្កកម្មដែលបានទទួលចំពោះតក្កកម្មតែមួយក្នុងប្រទេសផ្សេងៗគ្នា |
| មាត្រា៤ ស្ទួន៣: | ប្រកាសនីយបត្រតក្កកម្មៈ ការបង្ហាញឈ្មោះតក្កករនៅក្នុងប្រកាស-នីយបត្រតក្កកម្ម |
| មាត្រា៤ ស្ទួន៤: | ប្រកាសនីយបត្រតក្កកម្មៈ ភាពដែលអាចទទួលបានប្រកាសនីយ-បត្រតក្កកម្មក្នុងករណីដែលច្បាប់កម្រិតការលក់ |
| មាត្រា៥: | (ក) ប្រកាសនីយបត្រតក្កកម្មៈ ការនាំចូលទំនិញ ការមិនធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មមិនបានពេញលេញ អាជ្ញាប័ណ្ណបញ្ជា<br>(ខ) គំនូរឧស្សាហកម្មៈ ការមិនធ្វើអាជីវកម្ម ការនាំចូលទំនិញ<br>(គ) ម៉ាកៈ ការមិនប្រើប្រាស់ ទម្រង់ផ្សេងៗនៃម៉ាក ការប្រើប្រាស់ដោយសហកម្មសិទ្ធិករ<br>(ឃ) ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថ-ប្រយោជន៍ ម៉ាក គំនូរឧស្សាហកម្មៈ សញ្ញាសំគាល់ |
| មាត្រា៥ ស្ទួន២: | កម្មសិទ្ធិឧស្សាហកម្មទាំងអស់ៈ រយៈពេលអនុគ្រោះចំពោះការបង់កម្រៃកំណត់ដើម្បីរក្សាសិទ្ធិប្រកាសនីយបត្រតក្កកម្មៈ ការផ្តល់សិទ្ធិឡើងវិញ |
| មាត្រា៥ ស្ទួន៣: | ប្រកាសនីយបត្រតក្កកម្មៈ ឧបករណ៍ការពារដោយប្រកាសនីយបត្រ-តក្កកម្ម ដែលជាផ្នែកនៃ នាវា អាកាសយាន ឬយានយន្ត |


* មាតិកានេះត្រូវបានបន្ថែមដើម្បីជាជំនួយដល់អ្នកអានប៉ុណ្ណោះ។ ក្នុងអត្ថបទចុះហត្ថលេខានៃអនុសញ្ញានេះគ្មានមាតិកានេះទេ។

| | |
|---|---|
| មាត្រា៥ ស្ទួន៤: | ប្រកាសនីយបត្រកត្តកម្មៈ ការនាំចូលផលិតផលដែលផលិតដោយដំណើរផលិតកម្មដែលបានទទួលកិច្ចការពារដោយប្រកាសនីយបត្រ-តក្កកម្មនៅក្នុងប្រទេសនាំចូល |
| មាត្រា៥ ស្ទួន៥: | គំនូរឧស្សាហកម្ម |
| មាត្រា៦: | ម៉ាកៈ លក្ខខណ្ឌនៃការចុះបញ្ជី ឯករាជ្យនៃកិច្ចការពារម៉ាកដែលដូចគ្នាក្នុងប្រទេសផ្សេងៗគ្នា |
| មាត្រា៦ ស្ទួនៈ | ម៉ាកៈ ម៉ាកល្បី |
| មាត្រា៦ ស្ទួន៣: | ម៉ាកៈ ការហាមឃាត់ចំពោះ សញ្ញាជាតិ ត្រាផ្លូវការ និងនិមិត្តសញ្ញានៃអង្គការអន្តររដ្ឋាភិបាល |
| មាត្រា៦ ស្ទួន៤: | ម៉ាកៈ ការផ្ទេរសិទ្ធិនៃម៉ាក |
| មាត្រា៦ ស្ទួន៥: | ម៉ាកៈ កិច្ចការពារម៉ាកដែលបានចុះបញ្ជីក្នុងប្រទេសមួយនៃប្រទេសផ្សេងៗទៀតនៃសហភាព |
| មាត្រា៦ ស្ទួន៦: | ម៉ាកៈ សេវាសញ្ញា |
| មាត្រា៦ ស្ទួន៧: | ម៉ាកៈ ការចុះបញ្ជីដោយភ្នាក់ងារ ឬតំណាងនៃម្ចាស់ម៉ាកដោយគ្មានការអនុញ្ញាតពីម្ចាស់ម៉ាក |
| មាត្រា៧: | ប្រភេទនៃទំនិញដែលពាក់ម៉ាក |
| មាត្រា៧ ស្ទួនៈ | ម៉ាកៈ ម៉ាកសមូហភាព |
| មាត្រា៨: | ពាណិជ្ជនាម |
| មាត្រា៩: | ម៉ាក ពាណិជ្ជនាមៈ ការរឹបអូសទំនិញនាំចូល ។ល។ ដែលពាក់ម៉ាកឬពាណិជ្ជនាមខុសច្បាប់ |
| មាត្រា១០: | ការចង្អុលបង្ហាញមិនត្រឹមត្រូវ : ការរឹបអូសការនាំចូល ។ល។ នូវទំនិញដែលចង្អុលបង្ហាញមិនត្រឹមត្រូវពីប្រភពដើម ឬអត្តសញ្ញាណរបស់ផលិតករ |
| មាត្រា១០ ស្ទួនៈ | ការប្រកួតប្រជែងមិនស្មោះត្រង់ |
| មាត្រា១០ ស្ទួន៣: | ម៉ាក ពាណិជ្ជនាម ការចង្អុលបង្ហាញមិនត្រឹមត្រូវ ការប្រកួតប្រជែងមិនស្មោះត្រង់ៈ វិធានការដោះស្រាយ សិទ្ធិប្តឹង |
| មាត្រា១១: | តក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ម៉ាកៈ កិច្ចការពារបណ្តោះអាសន្នក្នុងពិពណ៌អន្តរជាតិមួយចំនួន |
| មាត្រា១២: | សេវាកម្មជាតិពិសេសចំពោះកម្មសិទ្ធិឧស្សាហកម្ម |

មាត្រា១៣:	សន្និបាតនៃសហភាព
មាត្រា១៤:	គណៈកម្មាធិការប្រតិបត្តិ
មាត្រា១៥:	ការិយាល័យអន្តរជាតិ
មាត្រា១៦:	ហិរញ្ញវត្ថុ
មាត្រា១៧:	វិសោធនកម្ម មាត្រា១៣ ដល់ មាត្រា១៧
មាត្រា១៨:	ការកែប្រែ មាត្រា១ដល់មាត្រា១២ និងមាត្រា១៨ដល់មាត្រា៣០
មាត្រា១៩:	កិច្ចព្រមព្រៀងពិសេស
មាត្រា២០:	ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយប្រទេសទាំងឡាយនៃសហភាព ការចូលជាធរមាន
មាត្រា២១:	ការចូលជាសមាជិកដោយប្រទេសក្រៅសហភាព ការចូលជាធរមាន
មាត្រា២២:	វិបាកនៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក
មាត្រា២៣:	ការចូលជាសមាជិកក្នុងច្បាប់មុនៗ
មាត្រា២៤:	ដែនដី
មាត្រា២៥:	ការអនុវត្តន៍អនុសញ្ញានៅថ្នាក់ជាតិ
មាត្រា២៦:	ការប្រកាសដកខ្លួនចេញ
មាត្រា២៧:	ការអនុវត្តច្បាប់មុនៗ
មាត្រា២៨:	ជម្លោះ
មាត្រា២៩:	ការចុះហត្ថលេខា ភាសា មុខងារនៃការតម្កល់
មាត្រា៣០:	អន្តរប្បញ្ញត្តិ

## មាត្រា ១

## [ការបង្កើតសហភាព វិសាលភាពនៃកម្មសិទ្ធិឧស្សាហកម្ម[1] ]

១- ប្រទេសជាសមាជិកទាំងឡាយនៃអនុសញ្ញានេះ ត្រូវបង្កើតសហភាពដើម្បីការពារកម្មសិទ្ធិឧស្សាហកម្ម។

២- កម្មសិទ្ធិឧស្សាហកម្ម មានកម្មវត្ថុការពារ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ម៉ាក សេវាសញ្ញា ពាណិជ្ជនាម ការសម្គាល់ប្រភព ឬការហៅតាមប្រភពដើម និងការប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់។

៣- កម្មសិទ្ធិឧស្សាហកម្មត្រូវយល់ក្នុងន័យទូលាយ ហើយត្រូវអនុវត្តមិនត្រឹមតែចំពោះវិស័យឧស្សាហកម្មនិងពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែត្រូវអនុវត្តផងដែរក្នុងវិស័យឧស្សាហកម្មកសិកម្មនិងឧស្សាហកម្មចំរ៉ាញ់ និងចំពោះផលិតផលការុណកម្មឬរាល់ផលិតផលធម្មជាតិ ដូចជា ស្រា ធញ្ញជាតិ ថ្នាំជក់ សត្វពាហនៈ រ៉ែ ទឹករ៉ែ ស្រាបៀ ផ្កា និងម្សៅមី។

៤- ប្រកាសនីយបត្រតក្កម្មត្រូវរួមបញ្ចូលនូវប្រភេទផ្សេងៗនៃប្រកាសនីយបត្រតក្កកម្មឧស្សាហកម្ម ដែលទទួលស្គាល់ដោយច្បាប់នៃប្រទេសជាសមាជិកទាំងឡាយនៃសហភាព ដូចជាប្រកាសនីយតក្កកម្មនៃការនាំចូល ប្រកាសនីយបត្រកត្កកម្មលើការអភិវឌ្ឍន៍តក្កកម្មចាស់ ប្រកាសនីយបត្រតក្កកម្មលើការបន្ថែមថ្មី និង វិញ្ញាបនបត្រលើការបន្ថែមថ្មី។ល។

## មាត្រា២

## [ ប្រព្រឹត្តិកម្មជាតិចំពោះពលរដ្ឋនៃប្រទេសជាសមាជិកសហភាព ]

១- ចំពោះកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ពលរដ្ឋនៃប្រទេសជាសមាជិកសហភាពត្រូវទទួលបានអត្ថប្រយោជន៍នានានៅក្នុងប្រទេសផ្សេងៗទៀតនៃសហភាព ដែលច្បាប់ប្រទេសទាំងនោះបានផ្តល់ឱ្យដល់ប្រជាពលរដ្ឋរបស់គេ ក្នុងពេលបច្ចុប្បន្ន ឬនឹងត្រូវផ្តល់ឱ្យនាពេលអនាគត នូវសិទ្ធិទាំងឡាយដែលមានចែងជាពិសេសក្នុងអនុសញ្ញានេះ ដោយគ្មានការរើសអើង។ ដូច្នេះ ពលរដ្ឋនៃប្រទេសជាសមាជិកសហភាពត្រូវទទួលបានកិច្ចការពារនិងវិធានការដោះស្រាយតាមច្បាប់ប្រឆាំងនឹងការរំលោភបំពានសិទ្ធិ ដូចគ្នា ទៅនឹងពលរដ្ឋនៃប្រទេសទាំងនោះ ឱ្យតែគោរពតាមលក្ខខណ្ឌនិងទម្រង់នានា ដែលមានក្នុងប្រទេសទាំង

[1] ការដាក់ចំណងជើងនៃគ្រប់មាត្រាគឺដើម្បីផ្តល់ភាពងាយស្រួលក្នុងការធ្វើអត្តសញ្ញាណកម្មតែប៉ុណ្ណោះ។ នៅក្នុងដែលអត្ថបទចុះហត្ថលេខា(ភាសាបារាំង)គ្មានចំណងជើងទេ។

នោះ។

២- ប៉ុន្តែ ដើម្បីការពារសិទ្ធិកម្មសិទ្ធិឧស្សាហកម្ម មិនតម្រូវឱ្យមានលក្ខខណ្ឌ លំនៅ-ឋាន ឬ គ្រឹះស្ថានចំពោះពលរដ្ឋនៃប្រទេសនានារបស់សហភាព នៅក្នុងប្រទេសដែលត្រូវសុំកិច្ចការពារនោះទេ។

៣- ត្រូវរក្សាទុកឱ្យបានដាក់លាក់ រាល់បទប្បញ្ញត្តិច្បាប់ប្រទេសនីយមួយៗនៃសហ-ភាព ទាក់ទងនឹងនីតិវិធីតុលាការ រដ្ឋបាល សមត្ថកិច្ច និងការកំណត់អាសយដ្ឋានចំពោះការផ្តល់សេវា ឬ ការចាត់តាំងភ្នាក់ងារ ដែលតម្រូវដោយច្បាប់ស្តីពីកម្មសិទ្ធិឧស្សាហកម្ម ។

## មាត្រា៣

**[ ប្រព្រឹត្តិកម្មដូចគ្នាចំពោះប្រភេទបុគ្គលមួយចំនួន ដូចពលរដ្ឋនៃប្រទេសក្នុងសហភាព ]**

ពលរដ្ឋនៃប្រទេសទាំងឡាយដែលមិនមែនជាសមាជិកនៃសហភាព ដែលមានទីលំនៅ ឬ មានគ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្ម ពិតប្រាកដនិងកំពុងដំណើរការ នៅក្នុងដែនដីណាមួយនៃប្រទេសជាសមាជិកសហភាព ត្រូវទទួលបានប្រព្រឹត្តិកម្មដូចគ្នានឹងពលរដ្ឋនៃប្រទេសជាសមាជិកសហភាព។

## មាត្រា៤

**[ (ក) ដល់ (ឈ) : ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ម៉ាក វិញ្ញាបនបត្រតក្កករ : សិទ្ធិអាទិភាព (ឆ) ប្រកាសនីយបត្រតក្កកម្ម: ការបំបែកសំណុំលិខិតស្នើសុំ ]**

ក.-

១- សម្រាប់ការដាក់ពាក្យសុំក្នុងប្រទេសដទៃ បុគ្គល ឬ អ្នកទទួលសិទ្ធិ ដែលដាក់ពាក្យសុំចុះបញ្ជីយ៉ាងត្រឹមត្រូវ នូវ ប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថ-ប្រយោជន៍ ឬ គំនូរឧស្សាហកម្ម ឬ ម៉ាក នៅក្នុងប្រទេសណាមួយនៃសហភាព ត្រូវទទួលបាននូវសិទ្ធិអាទិភាពក្នុងអំឡុងពេលកំណត់ ដូចមានចែងក្នុងអនុសញ្ញានេះ។

២- ការដាក់ពាក្យសុំដែលសមមូលនឹងការដាក់ពាក្យសុំធម្មតាថ្នាក់ជាតិ ក្រោមច្បាប់ជាតិនៃប្រទេសក្នុងសហភាព ឬ ក្រោមអនុសញ្ញាទ្វេភាគីឬពហុភាគី ដែលបង្កើតឡើងដោយប្រទេសជាសមាជិកទាំងឡាយនៃសហភាព ត្រូវទទួលបានសិទ្ធិអាទិភាព។

៣- ការដាក់ពាក្យសុំធម្មតាថ្នាក់ជាតិ មានន័យថា ការដាក់ពាក្យសុំណាមួយដែលមានលក្ខណៈត្រឹមត្រូវ ដែលបង្កើតបានជាកាលបរិច្ឆេទចំពោះការដាក់ពាក្យដែលបានធ្វើក្នុងប្រទេសដែលពាក់ព័ន្ធ ទោះបីបើការដាក់ពាក្យស្នើសុំនោះមានលទ្ធផលយ៉ាងណាក៏ដោយ។

**ខ.-** ការដាក់ពាក្យសុំបន្ទាប់ ក្នុងប្រទេសផ្សេងទៀតនៃសហភាព មុនផុតរយៈពេលកំណត់

ខាងលើ មិនត្រូវធ្វើមោឃភាព ដោយមូលហេតុនៃការធ្វើសកម្មភាពណាមួយ ក្នុងចន្លោះពេលនោះទេ ជាពិសេស ការដាក់ពាក្យសុំផ្សេងទៀត ការបោះពុម្ពផ្សាយ ការធ្វើអាជីវកម្មលើតក្កកម្ម ការដាក់លក់នៃគំនូរចម្លង ឬការប្រើប្រាស់ម៉ាក។ សកម្មភាពទាំងនេះ មិនអាចបង្កើតបានជាសិទ្ធិដល់តតិយជន ឬ កម្មសិទ្ធិផ្ទាល់ខ្លួនឡើយ។ សិទ្ធិដែលតតិយជនទទួលបានមុនកាលបរិច្ឆេទនៃសំណុំលិខិតស្នើសុំដំបូង ដែលជាមូលដ្ឋាននៃសិទ្ធិអាទិភាព ត្រូវរក្សាទុកតាមប្បញ្ញត្តិច្បាប់ជាតិនីមួយៗនៃប្រទេសក្នុងសហភាព។

**គ.-**

១- រយៈពេលអាទិភាពដូចចែងខាងលើ ត្រូវមានរយៈពេល១២(ដប់ពីរ)ខែចំពោះប្រកាសនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ហើយមានរយៈពេល៦(ប្រាំមួយ)ខែចំពោះគំនូរឧស្សាហកម្ម និងម៉ាក។

២- រយៈពេលទាំងនេះ ត្រូវរាប់ចាប់ផ្តើមពីកាលបរិច្ឆេទនៃការដាក់សំណុំលិខិតស្នើសុំដំបូង។ ថ្ងៃដាក់ពាក្យសុំមិនត្រូវរាប់បញ្ចូលក្នុងរយៈពេលនេះទេ។

៣- ប្រសិនបើថ្ងៃចុងក្រោយនៃរយៈពេលនេះជាថ្ងៃឈប់សម្រាកផ្លូវការ ឬ ជាថ្ងៃដែលការិយាល័យបិទមិនទទួលការដាក់សំណុំលិខិតស្នើសុំ នៅក្នុងប្រទេសសុំការពាររយៈពេលនេះ ត្រូវពន្យារហូតដល់ថ្ងៃធ្វើការបន្ទាប់ទីមួយ។

៤- សំណុំលិខិតស្នើសុំបន្ទាប់ទាក់ទងនឹងកម្មវត្ថុតែមួយ ដូចសំណុំលិខិតស្នើសុំដំបូងដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើ ដែលត្រូវបានដាក់ពាក្យសុំនៅក្នុងប្រទេសតែមួយនៃសហភាព ត្រូវចាត់ទុកជាសំណុំលិខិតស្នើសុំដំបូង។ កាលបរិច្ឆេទនៃការសុំចុះបញ្ជីត្រូវជាចំនុចចាប់ផ្តើមនៃរយៈពេលអាទិភាព ប្រសិនបើនៅពេលដែលដាក់ពាក្យសុំសំណុំលិខិតស្នើសុំបន្ទាប់ សំណុំលិខិតស្នើសុំពីមុននោះត្រូវបានដកយកទៅវិញ បោះបង់ចោល ឬបដិសេធ ដោយមិនដាក់ឱ្យសាធារណៈជនដឹង និងដោយមិនបើកសិទ្ធិបន្តទៀត ហើយប្រសិនបើសំណុំលិខិតស្នើសុំពីមុន មិនទាន់ត្រូវបានចាត់ទុកជាមូលដ្ឋានសម្រាប់អះអាងសិទ្ធិអាទិភាពនៅឡើយ។ ហេតុនេះ សំណុំលិខិតស្នើសុំមុននេះ មិនអាចចាត់ទុកជាមូលដ្ឋានដើម្បីទាមទារសិទ្ធិអាទិភាពបានឡើយ។

**ឃ.-**

១- បុគ្គលដែលចង់ទទួលអត្ថប្រយោជន៍ពីសិទ្ធិអាទិភាពនៃការដាក់ពាក្យសុំពីមុន តម្រូវឱ្យប្រកាសកាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះបញ្ជីនោះ និងប្រកាសប្រទេសដែលបានដាក់ពាក្យសុំ។ ប្រទេសនីមួយៗ ត្រូវកំណត់កាលបរិច្ឆេទចុងក្រោយនៃសេចក្តីប្រកាសនេះ។

២- លក្ខណៈដោយឡែកទាំងនេះ ត្រូវចុះក្នុងការបោះពុម្ពផ្សាយរបស់អាជ្ញាធរមានសមត្ថកិច្ច ហើយជាពិសេសក្នុងប្រកាសនីយបត្រតក្កកម្ម និងក្នុងសេចក្តីអធិប្បាយ។

៣- ប្រទេសទាំងឡាយនៃសហភាពអាចតម្រូវឱ្យបុគ្គលណាមួយដែលប្រកាសសិទ្ធិអាទិភាព ផ្តល់ច្បាប់ចម្លងនៃសំណុំលិខិតស្នើសុំ(សេចក្តីអធិប្បាយ គំនូសបង្ហាញ។ល។) ដែលបានដាក់ពីមុនមក។ ច្បាប់ចម្លងដែលបញ្ជាក់ថាត្រឹមត្រូវដោយអាជ្ញាធរដែលទទួលសំណុំលិខិតស្នើសុំនោះ មិនតម្រូវឱ្យមានយថាភាពណាមួយទេ ហើយអាចដាក់ពាក្យសុំដោយមិនគិតកម្រៃ តែក្នុងអំឡុងពេល៣(បី)ខែរាប់ចាប់ពីការដាក់សំណុំលិខិតស្នើសុំបន្ទាប់។ ប្រទេសនៃសហភាព អាចតម្រូវឱ្យសំណុំលិខិតស្នើសុំបន្ទាប់មានភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រដែលមានកាលបរិច្ឆេទសុំចុះបញ្ជី ហើយដែលចេញដោយអាជ្ញាធរ និងមានភ្ជាប់មកជាមួយនូវការបកប្រែផងដែរ។

៤- ពេលសុំចុះបញ្ជីសំណុំលិខិតស្នើសុំ មិនតម្រូវឱ្យមានលក្ខខណ្ឌទម្រង់ផ្សេងទៀតចំពោះការប្រកាសសិទ្ធិអាទិភាព។ ប្រទេសនីយមួយៗនៃសហភាពត្រូវកំណត់ផលវិបាកនៃការមិនគោរពតាមលក្ខខណ្ឌទម្រង់ដែលមានចែងក្នុងមាត្រានេះ ប៉ុន្តែផលវិបាកទាំងនេះអាចធ្វើឱ្យបាត់បង់សិទ្ធិអាទិភាពតែប៉ុណ្ណោះ។

៥- ប៉ុន្តែ អាចទាមទារឱ្យមានភស្តុតាងបន្ថែមទៀតបាន។

បុគ្គលណាមួយដែលប្រើប្រាស់សិទ្ធិអាទិភាពនៃសំណុំលិខិតស្នើសុំមុន តម្រូវឱ្យកំណត់លេខនៃសំណុំលិខិតស្នើសុំ។ លេខលិខិតនេះត្រូវបោះផ្សាយដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើ។

**ង.-**

១- នៅពេលគំនូរឧស្សាហកម្មមួយសុំចុះបញ្ជីក្នុងប្រទេសមួយដោយប្រើប្រាស់សិទ្ធិអាទិភាព នៃការដាក់ពាក្យសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ រយៈពេលអាទិភាពនេះ ត្រូវដូចគ្នានឹងរយៈពេលអាទិភាពដែលមានកំណត់ក្នុងគំនូរឧស្សាហកម្ម។

២- ជាងនេះទៅទៀត អាចអនុញ្ញាតឱ្យដាក់ពាក្យសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ក្នុងប្រទេសមួយ ដោយប្រើប្រាស់សិទ្ធិអាទិភាពនៃសុំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ហើយប្រកាសនីយបត្រតក្កកម្មក៏អាចប្រើប្រាស់សិទ្ធិអាទិភាពរបស់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ផងដែរ។

**ច.-** គ្មានប្រទេសណាមួយក្នុងសហភាពអាចបដិសេធសិទ្ធិអាទិភាព ឬសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ដោយមូលហេតុថាអ្នកដាក់ពាក្យបានអះអាងអំពីអាទិភាពច្រើនទោះបីបើអាទិភាពទាំងនេះមានក្នុងប្រទេសផ្សេងៗគ្នាក៏ដោយ ឬដោយមូលហេតុថាសំណុំ-

លិខិតស្នើសុំដែលបានអះអាងអំពីអាទិភាពមួយឬច្រើនមានធាតុមួយឬច្រើន ដែលមិនបានរៀបរាប់ក្នុងសំណុំលិខិតស្នើសុំ ឬ សំណុំលិខិតស្នើសុំទាំងឡាយ ដែលបានទាមទារអាទិភាព។ ក្នុងករណីទាំងពីរនេះត្រូវមានការរួមបញ្ចូលតែមួយនៃតក្កកម្មតាមអត្ថន័យនៃច្បាប់ជាតិរបស់ប្រទេសនីមួយៗ។

ចំពោះធាតុ ដែលគ្មានក្នុងសំណុំលិខិតស្នើសុំឬក្នុងសំណុំលិខិតស្នើសុំទាំងឡាយដែលបានទាមទារអាទិភាព ការដាក់សំណុំលិខិតស្នើសុំបន្ទាប់បង្កើតឱ្យមានសិទ្ធិអាទិភាពក្នុងលក្ខខណ្ឌធម្មតា។

**ឆ.-**

១- ប្រសិនបើការត្រួតពិនិត្យបង្ហាញថាសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មមានតក្កកម្មច្រើនជាងមួយ នោះអ្នកដាក់ពាក្យស្នើសុំអាចបំបែកសំណុំលិខិតស្នើសុំទៅជាសំណុំលិខិតស្នើសុំបំបែក ហើយអ្នកដាក់ពាក្យស្នើសុំអាចរក្សាកាលបរិច្ឆេទ ដូចកាលបរិច្ឆេទសំណុំលិខិតស្នើសុំដំបូង ហើយ ប្រសិនបើមាន ក៏អាចរក្សាផលប្រយោជន៍នៃសិទ្ធិអាទិភាពបានផងដែរ។

២- តាមគំនិតផ្តួចផ្តើមរបស់ខ្លួន អ្នកដាក់ពាក្យស្នើសុំអាចបំបែកសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងអាចរក្សាកាលបរិច្ឆេទនៃសំណុំលិខិតស្នើសុំបំបែកនីមួយៗដូចកាលបរិច្ឆេទសំណុំលិខិតស្នើសុំដំបូង ហើយ ប្រសិនបើមាន ក៏អាចរក្សាផលប្រយោជន៍នៃសិទ្ធិអាទិភាពបានផងដែរ។ ប្រទេសនីមួយៗនៃសហភាពមានសិទ្ធិកំណត់លក្ខខណ្ឌនៃការអនុញ្ញាតឱ្យបំបែកសំណុំលិខិតស្នើសុំបាន។

**ជ.-** អាទិភាពមិនអាចត្រូវបានបដិសេធដោយមូលហេតុថាធាតុមួយចំនួននៃតក្កកម្មដែលបានទាមទារសិទ្ធិអាទិភាព មិនបានកំណត់ក្នុងសេចក្តីអះអាងដែលបានសរសេរក្នុងសំណុំលិខិតស្នើសុំក្នុងប្រទេសដើម អោយតែឯកសារនៃសំណុំលិខិតស្នើសុំទាំងមូលបានបង្ហាញធាតុទាំងនោះយ៉ាងជាក់លាក់។

**ឈ.-**

១- សំណុំលិខិតស្នើសុំចំពោះវិញ្ញាបនបត្រតក្កករដែលបានដាក់ក្នុងប្រទេសមួយដោយអ្នកដាក់ពាក្យស្នើសុំ តាមជម្រើសរបស់ខ្លួន ដែលមានសិទ្ធិដាក់ពាក្យសុំជាប្រកាសនីយបត្រតក្កកម្មឬជាវិញ្ញាបនបត្រតក្កករ បង្កើតឱ្យមានសិទ្ធិអាទិភាពតាមអត្ថន័យនៃមាត្រានេះ ក្នុងលក្ខខណ្ឌដូចគ្នា និងអានុភាពដូចគ្នា ទៅនឹងសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម។

២- ក្នុងប្រទេសមួយ ដែលអ្នកដាក់ពាក្យស្នើសុំ តាមជម្រើសរបស់ខ្លួន មានសិទ្ធិដាក់

ជាប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រតក្កករ អនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ ចំពោះសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម អ្នកដែលដាក់ពាក្យសុំវិញ្ញាបនបត្រតក្ក-ករនឹងទទួលបានសិទ្ធិអាទិភាព ដោយផ្អែកលើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬ វិញ្ញាបនបត្រតក្កករ ។

## មាត្រា៤ ស្ទួន

## [ ប្រកាសនីយបត្រតក្កកម្មៈ ឯករាជ្យនៃប្រកាសនីយបត្រតក្កកម្មដែលបានទទួលចំពោះ តក្កកម្មតែមួយក្នុងប្រទេសផ្សេងៗគ្នា ]

១- ប្រកាសនីយបត្រតក្កកម្ម ដែលស្នើសុំនៅក្នុងប្រទេសផ្សេងៗគ្នា ដោយពលរដ្ឋនៃប្រទេសជាសមាជិកទាំងឡាយនៃសហភាព ត្រូវឯករាជ្យពីគ្នា ចំពោះការទទួលបានប្រកាសនីយបត្រតក្កកម្មលើតក្កកម្មតែមួយក្នុងប្រទេសផ្សេងៗគ្នានោះ ទោះបីជាប្រទេសជាសមាជិកសហភាពឬមិនមែនក៏ដោយ។

២- បទប្បញ្ញត្តិខាងលើនេះត្រូវបកស្រាយក្នុងន័យទូលាយ ជាពិសេសក្នុងលក្ខណៈដែលប្រកាសនីយបត្រតក្កកម្មដែលស្នើសុំក្នុងអំឡុងពេលអាទិភាព ត្រូវឯករាជ្យ ទាំងមូលហេតុមោឃភាពនិងការបាត់បង់សិទ្ធិ និងទាំងក្នុងអំឡុងពេលធម្មតា។

៣- បទប្បញ្ញត្តិនេះត្រូវអនុវត្តចំពោះ ប្រកាសនីយបត្រតក្កកម្មដែលមានពីមុនទាំងអស់ ពេលបទប្បញ្ញត្តិនេះចូលជាធរមាន។

៤- ដូចគ្នានេះដែរ ចំពោះប្រទេសដែលចូលជាសមាជិកថ្មីទាំងឡាយ បទប្បញ្ញត្តិនេះត្រូវអនុវត្តចំពោះប្រកាសនីយបត្រតក្កកម្មដែលមានពីមុនទាំងឡាយ ពេលចូលជាសមា-ជិក ។

៥- ប្រកាសនីយបត្រតក្កកម្ម ដែលបានទទួលផលប្រយោជន៍ពីសិទ្ធិអាទិភាពនៅក្នុងប្រទេសផ្សេងៗនៃសហភាព ត្រូវមានរយៈពេលការពារដូចគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្មដែលបានដាក់ពាក្យសុំ ឬបានផ្តល់ឱ្យ ដោយគ្មានទទួលផលប្រយោជន៍ពីសិទ្ធិអាទិ-ភាព។

## មាត្រា៤ ស្ទួន ៣

## [ ប្រកាសនីយបត្រតក្កកម្មៈ ការដាក់ឈ្មោះតក្កករនៅក្នុងប្រកាសនីយបត្រតក្កកម្ម ]

តក្កករត្រូវមានសិទ្ធិដាក់ឈ្មោះរបស់ខ្លួនក្នុងប្រកាសនីយបត្រតក្កកម្ម។

## មាត្រា៤ ស្ទួន ៤

## [ ប្រកាសនីយបត្រតក្កកម្មៈ ភាពដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្មក្នុងករណីដែលច្បាប់កម្រិតការលក់ ]

ការផ្តល់ប្រកាសនីយបត្រតក្កកម្មមិនត្រូវបានបដិសេធ ហើយប្រកាសនីយបត្រតក្ក-

កម្មក៏មិនត្រូវបានធ្វើមោឃភាពដោយមូលហេតុថាការលក់ផលិតផលឬការលក់ផលិតផលនៃដំណើរការផលិតកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្ម ជាកម្មវត្ថុនៃការរឹតត្បិតឬការកម្រិតរបស់ច្បាប់ជាតិ។

## មាត្រា៥

### [ (ក) ប្រកាសនីយបត្រតក្កកម្ម: ការនាំចូលទំនិញ ការមិនធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មមិនបានពេញលេញ អាជ្ញាប័ណ្ណបញ្ជា (ខ) គំនូរឧស្សាហកម្ម: ការមិនធ្វើអាជីវកម្ម ការនាំចូលទំនិញ (គ) ម៉ាក: ការមិនប្រើប្រាស់ ទម្រង់ផ្សេងៗនៃម៉ាក ការប្រើប្រាស់ ដោយសហកម្មសិទ្ធិករ (ឃ) ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ម៉ាក គំនូរឧស្សាហកម្ម: សញ្ញាសំគាល់ ]

ក.-

១- ការនាំចូលដោយម្ចាស់ប្រកាសនីយបត្រតក្កកម្មក្នុងប្រទេស ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម នូវទំនិញដែលបានផលិតក្នុងប្រទេសណាមួយនៃសហភាពនឹងមិនធ្វើឱ្យបាត់បង់សិទ្ធិលើប្រកាសនីយបត្រតក្កកម្មឡើយ។

២- ប្រទេសនីមួយៗនៃសហភាពមានសិទ្ធិចាត់វិធានការតាមផ្លូវច្បាប់ ចំពោះការផ្តល់អាជ្ញាប័ណ្ណបញ្ជា ដើម្បីបង្កាការរំលោភបំពាន ដែលអាចកើតឡើងពីការអនុវត្តន៍សិទ្ធិផ្តាច់មុខដែលបានផ្តល់ដោយប្រកាសនីយបត្រតក្កកម្ម ដូចជាការមិនធ្វើអាជីវកម្មជាដើម។

៣- ការបាត់បង់សិទ្ធិលើប្រកាសនីយបត្រតក្កកម្មអាចកើតមាន តែក្នុងករណីដែលការផ្តល់អាជ្ញាប័ណ្ណបញ្ជាមានលក្ខណៈមិនគ្រប់គ្រាន់ ដើម្បីបង្កាការរំលោភបំពាននោះ។ មិនអាចប្តឹងធ្វើមោឃភាព ឬប្តឹងដកប្រកាសនីយបត្រតក្កកម្ម មុនផុតរយៈពេល២(ពីរ)ឆ្នាំ ដោយរាប់ចាប់ពីពេលផ្តល់អាជ្ញាប័ណ្ណបញ្ជាដំបូងឡើយ។

៤- អាជ្ញាប័ណ្ណបញ្ជាមិនអាចស្នើសុំបានទេដោយមូលហេតុការមិនធ្វើអាជីវកម្ម ឬការធ្វើអាជីវកម្មមិនបានពេញលេញមុនផុតរយៈពេល៤(បួន)ឆ្នាំ គិតពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬ ៣(បី)ឆ្នាំគិតពីកាលបរិច្ឆេទផ្តល់ប្រកាសនីយ-បត្រតក្កកម្ម ដោយយកកាលបរិច្ឆេទណាមួយដែលផុតកំណត់ក្រោយគេ។ អាជ្ញាប័ណ្ណបញ្ជាមិនត្រូវបានចេញអោយទេ ប្រសិនបើម្ចាស់ប្រកាសនីយបត្រតក្កកម្មបានបំភ្លឺពីការមិនធ្វើសកម្មភាពរបស់ខ្លួនដោយហេតុផលត្រឹមត្រូវតាមច្បាប់។ អាជ្ញាប័ណ្ណបញ្ជានេះត្រូវមានលក្ខណៈមិនផ្តាច់មុខហើយមិនអាចផ្ទេរបានឡើយ ទោះបីក្នុងទម្រង់ជាអាជ្ញាប័ណ្ណបន្តក៏ដោយ លើកលែងតែការផ្ទេរទៅផ្នែកមួយរបស់សហគ្រាស ឬ មូលនិធិពាណិជ្ជកម្មដែលធ្វើអាជីវកម្មលើអាជ្ញាបញ្ជានោះ។

៥- បទប្បញ្ញត្តិខាងលើនេះ ត្រូវអនុវត្តដូចគ្នាចំពោះវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍។

**ខ.-** ក្នុងកាលៈទេសៈណាក៏ដោយ កិច្ចការពារគំនូរឧស្សាហកម្ម មិនត្រូវបាត់បង់ឡើយ ដោយមូលហេតុ ការមិនធ្វើអាជីវកម្ម ឬដោយការនាំចូលនូវទំនិញដែលដូចនឹងទំនិញដែលបានការពារ។

**គ.-**

១- ក្នុងប្រទេសណាមួយ បើតម្រូវឱ្យមានការប្រើប្រាស់ម៉ាកដែលបានចុះបញ្ជី ការចុះបញ្ជីអាចត្រូវបានលុបចោលតែក្នុងរយៈពេលសមស្របមួយ ហើយបើបុគ្គលដែលពាក់ព័ន្ធមិនបានផ្តល់ហេតុផលសមស្របអំពីការមិនបានប្រើប្រាស់ម៉ាកនោះ។

២- ការប្រើប្រាស់ម៉ាកដោយម្ចាស់ម៉ាកក្នុងទម្រង់នៃធាតុបំប្លែង ដែលមិនបណ្តាលឱ្យផ្លាស់ប្តូរលក្ខណៈអាចញែកដាច់ពីគ្នាបាននៃម៉ាកក្នុងទម្រង់ ដែលបានចុះបញ្ជីក្នុងប្រទេសណាមួយនៃសហភាព មិនធ្វើឱ្យមោឃៈចំពោះការចុះបញ្ជីហើយក៏មិនបន្ថយកិច្ចការពារចំពោះម៉ាកនោះបានឡើយ។

៣- ការប្រើប្រាស់ជាន់គ្នានៃម៉ាកដូចគ្នាលើទំនិញដែលដូចគ្នាឬស្រដៀងគ្នាដោយសហគ្រាសឧស្សាហកម្ម ឬពាណិជ្ជកម្មទាំងឡាយដែលត្រូវចាត់ទុកថាជាសហកម្មសិទ្ធិករនៃម៉ាកនេះ តាមបទប្បញ្ញត្តិច្បាប់ជាតិនៃប្រទេសដែលអះអាងឱ្យការពារ មិនត្រូវរារាំងដល់ការចុះបញ្ជីឬបន្ថយកិច្ចការពារចំពោះម៉ាកក្នុងប្រទេសណាមួយនៃសហភាព ឱ្យតែការប្រើប្រាស់នោះ មិននាំឱ្យមានការភ័ន្តច្រឡំដល់សាធារណៈជននិងមិនផ្ទុយនឹងផលប្រយោជន៍សាធារណៈ។

**ឃ.-** មិនតម្រូវឱ្យមានការបង្ហាញ ឬនិទ្ទេសនៃប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការចុះបញ្ជីម៉ាក ឬការតម្កល់គំនូរឧស្សាហកម្ម លើទំនិញជាលក្ខខណ្ឌដើម្បីឱ្យមានការទទួលស្គាល់សិទ្ធិដែលត្រូវការពារនោះទេ។

## មាត្រា៥ ស្ទួន

## [ កម្មសិទ្ធិឧស្សាហកម្មទាំងអស់: រយៈពេលអនុគ្រោះចំពោះការបង់កម្រៃដើម្បីរក្សាសិទ្ធិប្រកាសនីយបត្រតក្កកម្ម: ការផ្តល់សិទ្ធិឡើងវិញ ]

១- រយៈពេលអនុគ្រោះមិនតិចជាង៦(ប្រាំមួយ)ខែ ត្រូវបានអនុញ្ញាតចំពោះការបង់កម្រៃដែលបានកំណត់ដើម្បីរក្សាសិទ្ធិកម្មសិទ្ធិឧស្សាហកម្ម លើកលែងតែច្បាប់ជាតិចែងអំពីការបង់កម្រៃបន្ថែម។

២- ប្រទេសទាំងឡាយនៃសហភាព មានសិទ្ធិកំណត់ ការផ្តល់សិទ្ធិឡើងវិញលើ

ប្រកាសនីយបត្រតក្កកម្ម ដែលបាត់សុពលភាពដោយមូលហេតុមិនបង់កម្រៃ។

## មាត្រា៥ ស្ទួន ៣

## [ ប្រកាសនីយបត្រតក្កកម្មៈ ឧបករណ៍ការពារដោយប្រកាសនីយបត្រតក្កកម្ម ដែលជាផ្នែកនៃ នាវា អាកាសយាន ឬយានយន្ត ]

ក្នុងប្រទេសណាមួយនៃសហភាព ការប្រើប្រាស់ដូចខាងក្រោម មិនត្រូវចាត់ទុកជាការរំលោភបំពានសិទ្ធិម្ចាស់ប្រកាសនីយបត្រតក្កកម្មៈ

១- ការប្រើប្រាស់លើនាវានៃប្រទេសផ្សេងនៃសហភាពនូវឧបករណ៍ដែលការពារដោយប្រកាសនីយបត្រតក្កកម្មនៅក្នុងតួនៃនាវា នៅក្នុងម៉ាស៊ីន រ៉ក ស្ពឺនិងឧបករណ៍បន្ទាប់បន្សំផ្សេងទៀត នៅពេលដែលនាវានោះចូលចតជាបណ្តោះអាសន្ន ឬដោយឧបទ្វ-ហេតុក្នុងដែនទឹកនៃប្រទេសនោះ ឱ្យតែឧបករណ៍ទាំងនោះត្រូវបានប្រើប្រាស់សម្រាប់តែតម្រូវការនៃនាវា។

២- ការប្រើប្រាស់ឧបករណ៍ដែលជាកម្មវត្ថុការពារដោយប្រកាសនីយបត្រតក្កកម្មនៅក្នុងការជួសជុល ឬក្នុងដំណើរការនៃអាកាសយាន យានយន្តនៃប្រទេសផ្សេងនៃសហភាព ឬនៃឧបករណ៍បន្ទាប់បន្សំផ្សេងទៀតនៃអាកាសយាន ឬយានយន្ត នៅពេលដែលអាកាសយានឬយានយន្តទាំងនោះចូលចតជាបណ្តោះអាសន្ន ឬដោយឧបទ្វវហេតុក្នុងប្រទេសនោះ។

## មាត្រា៥ ស្ទួន ៤

## [ ប្រកាសនីយបត្រកក្កកម្មៈ ការនាំចូលផលិតផលដែលផលិតដោយដំណើរការផលិតកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសនាំចូល ]

នៅពេលដែលផលិតផលមួយ ត្រូវបាននាំចូលក្នុងប្រទេសមួយនៃសហភាពដែលដំណើរការផលិតកម្មត្រូវបានការពារដោយប្រកាសនីយបត្រតក្កកម្មចំពោះការផលិតផលិតផលនោះ ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិគ្រប់យ៉ាងចំពោះផលិតផលនាំចូលដែលច្បាប់នៃប្រទេសនាំចូលបានផ្តល់ឱ្យ លើមូលដ្ឋាននៃដំណើរការផលិតកម្ម ចំពោះផលិតផលផលិតក្នុងប្រទេសនោះ។

## មាត្រា៥ ស្ទួន ៥

## [ គំនូរឧស្សាហកម្ម ]

គំនូរឧស្សាហកម្មត្រូវបានការពារនៅក្នុងប្រទេសទាំងឡាយនៃសហភាព។

## មាត្រា៦

## [ ម៉ាកៈ លក្ខខណ្ឌនៃការចុះបញ្ជី ឯករាជ្យនៃកិច្ចការពារម៉ាកដែលដូចគ្នាក្នុងប្រទេសផ្សេងៗគ្នា ]

១- លក្ខខណ្ឌសម្រាប់ការដាក់ពាក្យ និងចុះបញ្ជីម៉ាកត្រូវកំណត់ក្នុងប្រទេសនីមួយៗនៃសហភាពដោយច្បាប់ជាតិរបស់ខ្លួន។

២- ម្យ៉ាងវិញទៀត ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលធ្វើឡើងដោយពលរដ្ឋនៃប្រទេសរបស់សហភាព នៅក្នុងប្រទេសមួយផ្សេងទៀតនៃសហភាព មិនអាចត្រូវបានបដិសេធ ហើយការចុះបញ្ជីម៉ាកមិនត្រូវបានធ្វើមោឃភាព ដោយមូលហេតុថាការដាក់ពាក្យស្នើសុំចុះបញ្ជី ការចុះបញ្ជី ឬការចុះបញ្ជីសាជាថ្មី មិនបានធ្វើនៅក្នុងប្រទេសដើម។

៣- ម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវក្នុងប្រទេសមួយនៃសហភាព ត្រូវឯករាជ្យពីម៉ាកដែលបានចុះបញ្ជីនៅក្នុងប្រទេសផ្សេងទៀតនៃសហភាព រួមបញ្ចូលទាំងប្រទេសដើម។

## មាត្រា៦ ស្ទួន

## [ ម៉ាកៈ ម៉ាកល្បី ]

១- ប្រទេសទាំងឡាយនៃសហភាព អាចធ្វើដោយខ្លួនឯងបើច្បាប់ជាតិអនុញ្ញាត ឬតាមសំណើរបស់ភាគីដែលពាក់ព័ន្ធ សន្យាបដិសេធ ឬលុបចោលការចុះបញ្ជី និងហាមឃាត់ការប្រើប្រាស់ម៉ាកណាមួយដែលជាការក្លែង ការត្រាប់តាម ការបកប្រែ ឬការប្រើប្រាស់ ដែលធ្វើឱ្យមានការភ័ន្តច្រឡំទៅនឹងម៉ាក ដែលអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនៃការចុះបញ្ជីបានចាត់ទុកជាម៉ាកល្បី ដែលជាម៉ាករបស់បុគ្គលទទួលបានអត្ថប្រយោជន៍ពីអនុសញ្ញានេះ ហើយត្រូវបានប្រើប្រាស់ចំពោះទំនិញដែលដូចគ្នាឬប្រហាក់ប្រហែលគ្នា។ បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ នៅពេលដែលផ្នែកសំខាន់នៃម៉ាកកើតចេញមកពីការក្លែងម៉ាកល្បីនោះ ឬការត្រាប់តាមដែលធ្វើឱ្យមានការភ័ន្តច្រឡំជាមួយម៉ាកល្បីនោះ។

២- ការអនុញ្ញាតចំពោះការស្នើសុំលុបចោលម៉ាកនោះត្រូវមានរយៈពេលយ៉ាងហោចណាស់ប្រាំ(៥)ឆ្នាំ ដោយរាប់ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី។ ប្រទេសទាំងឡាយនៃសហភាពអាចបញ្ញត្តិអំពីរយៈពេលនៃការតវ៉ាចំពោះការហាមឃាត់នៃការប្រើប្រាស់បាន។

៣- គ្មានអាជ្ញាយុកាលចំពោះការស្នើសុំលុបចោល ឬការហាមឃាត់នៃការប្រើប្រាស់ម៉ាកដែលបានចុះបញ្ជី ឬម៉ាកដែលបានប្រើប្រាស់ ក្នុងចេតនាទុច្ចរិត។

## មាត្រា៦ ស្ទួន ៣

## [ ម៉ាកៈ ការហាមឃាត់ចំពោះ និមិត្តរូបជាតិ ត្រាផ្លូវការ និងនិមិត្តរូបនៃអង្គការអន្តររដ្ឋាភិបាល ]

១-

ក- ប្រទេសទាំងឡាយនៃសហភាពយល់ព្រមបដិសេធ ឬធ្វើមោឃភាពការចុះបញ្ជី និងហាមឃាត់ តាមវិធានការសមស្រប ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមាន

សមត្ថកិច្ច ចំពោះការប្រើប្រាស់ម៉ាក ឬធាតុរបស់ម៉ាក សញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបជាតិផ្សេងៗទៀតនៃប្រទេសទាំងឡាយក្នុងសហភាព សញ្ញានិងត្រាផ្លូវការដែលបញ្ជាក់ពីការគ្រប់គ្រងនិងការធានា ដែលអនុម័តដោយប្រទេសទាំងនោះ និងការត្រាប់តាមសញ្ញាទាំងនេះ។

ខ- បទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ក)ខាងលើ ត្រូវអនុវត្តផងដែរ ចំពោះសញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗទៀត អក្សរកាត់ និងឈ្មោះនៃអង្គការអន្តរជាតិអន្តររដ្ឋាភិបាលដែលប្រទេសមួយឬច្រើននៃសហភាពជាសមាជិក លើកលែងតែសញ្ញាជាតិ ទង់-ជាតិ និមិត្តរូបផ្សេងៗទៀត អក្សរកាត់ និងឈ្មោះ ជាកម្មវត្ថុនៃកិច្ចការពារក្នុងកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន។

គ- មិនតម្រូវឱ្យប្រទេសណាមួយនៃសហភាពអនុវត្តបទប្បញ្ញត្តិនៃអនុកថា-ខណ្ឌ(ខ)ខាងលើ ដែលធ្វើឱ្យប៉ះពាល់ដល់ម្ចាស់សិទ្ធិសុច្ចរិត មុនការចូលជាធរមាននៃអនុ-សញ្ញានេះក្នុងប្រទេសនោះ។ មិនតម្រូវឱ្យប្រទេសទាំងឡាយនៃសហភាពអនុវត្តបទប្បញ្ញត្តិនេះ នៅពេលដែលការប្រើប្រាស់ ឬការចុះបញ្ជីដូចមានចែងក្នុងអនុកថាខណ្ឌ(ក)ខាងលើ មិនធ្វើឱ្យសាធារណៈជនយល់ថាមានទំនាក់ទំនងរវាងអង្គការនោះនិងសញ្ញាជាតិ ទង់ជាតិ និមិត្តរូបផ្សេងៗ អក្សរកាត់ និងឈ្មោះ ឬប្រសិនបើ ការប្រើប្រាស់ ឬការចុះបញ្ជី មិនធ្វើឱ្យសាធារណៈជនភ័ន្តច្រឡំថាមានទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និងអង្គការ។

២- ការហាមឃាត់ការប្រើប្រាស់សញ្ញានិងត្រាផ្លូវការ ដែលបញ្ជាក់ពីការគ្រប់គ្រងនិងការធានា អនុវត្តបាន តែក្នុងករណីដែលម៉ាកដែលពាក់សញ្ញានោះ មានគោលដៅប្រើប្រាស់លើទំនិញដែលដូចគ្នាឬប្រហាក់ប្រហែលគ្នា។

៣-

ក- ដើម្បីអនុវត្តបទប្បញ្ញត្តិទាំងនេះ ប្រទេសទាំងឡាយនៃសហភាព យល់ព្រមជូនដំណឹងឱ្យគ្នាទៅវិញទៅមក តាមរយៈការិយាល័យអន្តរជាតិ នូវបញ្ជីនៃនិមិត្តរូបជាតិ សញ្ញានិងត្រាផ្លូវការដែលបញ្ជាក់ពីការគ្រប់គ្រងនិងការធានា។ ដើម្បីឱ្យមាត្រានេះការពារប្រទេសទាំងឡាយ ដាក់ ឬអាចដាក់កម្រិតខ្លះឬទាំងស្រុង និងរាល់ការកែប្រែនានាក្នុងបញ្ជីនេះបាន។ ប្រទេសនីមួយៗនៃសហភាពត្រូវផ្តល់ដល់សាធារណៈនូវបញ្ជីនៃការជូនដំណឹងទាំងនេះក្នុងរយៈពេលមួយសមស្រប។

ប៉ុន្តែ មិនតម្រូវឱ្យជូនដំណឹងទេចំពោះទង់ជាតិនៃរដ្ឋនីមួយៗ។

ខ- បទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ) នៃកថាខណ្ឌ(១) នៃមាត្រានេះ ត្រូវអនុវត្តតែចំពោះសញ្ញាជាតិ ទង់ជាតិ និមិត្តរូបផ្សេងៗទៀត អក្សរកាត់ និង ឈ្មោះនៃអង្គការអន្តរ-

ជាតិអន្តររដ្ឋាភិបាល នៅពេលដែលអង្គការនេះ បានជូនដំណឹងទៅប្រទេសទាំងឡាយនៃសហភាពតាមរយៈការិយាល័យអន្តរជាតិ។

៤- ក្នុងរយៈពេល១២ខែរាប់ចាប់ពីពេលបានទទួលការជូនដំណឹង ប្រទេសណាមួយនៃសហភាព អាចបញ្ជូនលិខិតបដិសេធរបស់ខ្លួន តាមរយៈការិយាល័យអន្តរជាតិទៅប្រទេស ឬទៅអង្គការអន្តរជាតិអន្តររដ្ឋាភិបាលដែលពាក់ព័ន្ធ។

៥- ចំពោះទង់ជាតិនៃរដ្ឋ វិធានដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ត្រូវអនុវត្តតែចំពោះម៉ាកដែលបានចុះបញ្ជីក្រោយថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩២៥។

៦- ចំពោះនិមិត្តរូបជាតិក្រៅពីទង់ជាតិ ចំពោះសញ្ញានិងត្រាផ្លូវការនៃប្រទេសនៃសហភាព និងចំពោះសញ្ញាជាតិ ទង់ជាតិ និមិត្តរូបផ្សេងៗទៀត អក្សរកាត់និងឈ្មោះនៃអង្គការអន្តរជាតិអន្តររដ្ឋាភិបាល បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តតែចំពោះម៉ាកដែលបាន ចុះបញ្ជីក្នុងរយៈពេលលើសពី ២(ពីរ)ខែបន្ទាប់ពីទទួលបានការជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើ។

៧- ក្នុងករណីនៃចេតនាទុច្ចរិត ប្រទេសទាំងឡាយមានសិទ្ធិលុបចោលម៉ាកដែលមាននិមិត្តរូប សញ្ញានិងត្រាជាតិ ទោះបីត្រូវបានចុះបញ្ជីមុនថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩២៥ ក៏ដោយ។

៨- ពលរដ្ឋនៃប្រទេសណាមួយដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់និមិត្តរូប សញ្ញានិងត្រាជាតិនៃប្រទេសរបស់ពួកគេ អាចប្រើប្រាស់សញ្ញាទាំងនោះបាន ទោះបីបើសញ្ញាទាំងនេះដូចគ្នាទៅនឹងសញ្ញានៃប្រទេសដទៃទៀតក៏ដោយ។

៩- ប្រទេសទាំងឡាយនៃសហភាព សន្យាហាមឃាត់ការប្រើប្រាស់ដោយគ្មានការអនុញ្ញាតក្នុងពាណិជ្ជកម្មនូវសញ្ញាជាតិនៃប្រទេសដទៃក្នុងសហភាព នៅពេលដែលការប្រើប្រាស់នេះធ្វើឱ្យមានការភ័ន្តច្រឡំចំពោះប្រភពដើមនៃទំនិញ។

១០- បទប្បញ្ញត្តិខាងលើមិនត្រូវរារាំងប្រទេសទាំងឡាយ មិនឱ្យអនុវត្តសិទ្ធិដែលមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៦ ស្ទួន៥ ផ្នែក(ខ) ដើម្បីបដិសេធឬមោឃភាពការចុះបញ្ជីម៉ាកដែលមាន សញ្ញាជាតិ ទង់ជាតិ និមិត្តរូបជាតិផ្សេងៗទៀត សញ្ញានិងត្រាផ្លូវការដោយគ្មានការអនុញ្ញាត ដែលអនុម័តដោយប្រទេសនៃសហភាព ក៏ដូចជាសញ្ញាផ្សេងៗនៃអង្គការអន្តរជាតិអន្តររដ្ឋាភិបាល ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។

## មាត្រា៦ ស្ទួន ៤

### [ម៉ាក: ការផ្ទេរសិទ្ធិនៃម៉ាក]

១- តាមច្បាប់នៃប្រទេសនីមួយៗរបស់សហភាព ការផ្ទេរម៉ាកមានសុពលភាពតែក្នុង

ករណីដែលការផ្ទេរនោះ ធ្វើឡើងក្នុងពេលជាមួយគ្នានឹងការផ្ទេរអាជីវកម្ម ឬមូលនិធិពាណិជ្ជកម្ម ដែលមានម៉ាកនោះ។ ដើម្បីឱ្យមានសុពលភាព ទាមទារឱ្យផ្នែកនៃអាជីវកម្មឬមូលនិធិពាណិជ្ជកម្មដែលស្ថិតនៅក្នុងប្រទេសនោះ ត្រូវផ្ទេរទៅឱ្យអនុប្បទានិក រួមទាំងសិទ្ធិផ្តាច់មុខដើម្បីផលិតឬលក់ក្នុងប្រទេសនោះ នូវទំនិញពាក់ម៉ាកដែលបានផ្ទេរនោះ។

២- បទប្បញ្ញត្តិនេះ មិនដាក់កាតព្វកិច្ចលើប្រទេសទាំងឡាយនៃសហភាព ឱ្យទទួលស្គាល់សុពលភាពនៃម៉ាក ដែលអនុប្បទានិកប្រើប្រាស់ នាំឱ្យមានការភ័ន្តច្រឡំដល់សាធារណៈជន ជាពិសេសចំពោះប្រភពដើម លក្ខណៈ ឬគុណភាពសំខាន់នៃទំនិញដែលពាក់ម៉ាកនោះ។

## មាត្រា៦ ស្ទួន ៥

**[ម៉ាកៈកិច្ចការពារម៉ាកដែលបានចុះបញ្ជីក្នុងប្រទេសមួយ នៃប្រទេសផ្សេងទៀតនៃសហភាព]**

**ក.-**

១- រាល់ម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវក្នុងប្រទេសដើម នឹងត្រូវទទួលចុះបញ្ជី និងការពារនៅក្នុងប្រទេសផ្សេងទៀតនៃសហភាព លើកលែងតែចំពោះខដាក់លក្ខខណ្ឌដូចមានចែងក្នុងមាត្រានេះ។ មុនពេលចុះបញ្ជីឱ្យ ប្រទេសទាំងនេះអាចតម្រូវឱ្យផ្តល់វិញ្ញាបនបត្រចុះបញ្ជីក្នុងប្រទេសដើម ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ វិញ្ញាបនបត្រនេះមិនតម្រូវឱ្យមានយថាភាពទេ។

២- ត្រូវបានចាត់ទុកជាប្រទេសដើម គឺប្រទេសនៃសហភាពដែលអ្នកដាក់ពាក្យសុំចុះបញ្ជីមានគ្រឹះស្ថានឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការ ឬបើគ្មានគ្រឹះស្ថានទាំងនេះក្នុងសហភាពទេ គឺប្រទេសនៃសហភាពដែលគាត់មានលំនៅឋាន ឬបើគ្មានលំនៅឋាននៅក្នុងសហភាពទេប៉ុន្តែជាពលរដ្ឋនៃប្រទេសមួយក្នុងសហភាព គឺប្រទេសដែលគាត់ជាពលរដ្ឋនោះ។

**ខ.-** ម៉ាកដែលចែងក្នុងមាត្រានេះ មិនត្រូវបានបដិសេធការចុះបញ្ជី ឬធ្វើមោឃភាព លើកលែងតែក្នុងករណីដូចខាងក្រោមៈ

១- នៅពេលដែលម៉ាកនោះរំលោភសិទ្ធិ របស់តតិយជនក្នុងប្រទេសដែលអះអាងឱ្យការពារ។

២- នៅពេលដែលម៉ាកនោះបាត់បង់លក្ខណៈញែកដាច់ពីគ្នា ឬមានយ៉ាងជាក់លាក់នូវសញ្ញាឬការសំគាល់ ដែលនៅក្នុងពាណិជ្ជកម្ម បង្ហាញពី ប្រភេទ គុណភាព បរិមាណ គោលដៅ តំលៃ ប្រភពទីកន្លែងនៃទំនិញឬពេលវេលាផលិត ឬម៉ាកទាំងនេះបានក្លាយទៅជាពាក្យទូទៅក្នុងភាសាណាមួយក្នុងពេលបច្ចុប្បន្ន ឬ ក្នុងការប្រើប្រាស់ដោយសុច្ចរិតហើយ

បានក្លាយទៅជាការប្រើប្រាស់ជាទំលាប់ ក្នុងពាណិជ្ជកម្មរបស់ប្រទេសដែលអះអាងឱ្យការពារ។

៣- នៅពេលដែលម៉ាកនោះ ផ្ទុយនឹងសីលធម៌ឬសណ្តាប់ធ្នាប់សាធារណៈ ហើយជាពិសេសនាំឱ្យសាធារណៈជនភ័ន្តច្រឡំ។ ត្រូវយល់ថា ម៉ាកមួយមិនចាត់ទុកថាផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈដោយមូលហេតុតែមួយគត់ថា ម៉ាកនោះមិនអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីម៉ាកទេ លើកលែងតែបទប្បញ្ញត្តិនេះទាក់ទងតែម្តងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។

ប៉ុន្តែ បទប្បញ្ញត្តិនេះត្រូវលើកលែងចំពោះការអនុវត្តនៃមាត្រា១០ស្ទួន។

**គ.-**

១- ដើម្បីកំណត់ថាម៉ាកមួយអាចការពារបាន គេត្រូវពិចារណាលើកាលៈទេសៈជាក់ស្តែងទាំងអស់ ជាពិសេសរយៈពេលនៃការប្រើប្រាស់ម៉ាកនេះ។

២- មិនអាចបដិសេធការចុះបញ្ជីម៉ាកនៅក្នុងប្រទេសផ្សេងទៀតនៃសហភាពដោយមូលហេតុតែមួយគត់ថា ម៉ាកនេះខុសពីម៉ាកដែលបានការពារក្នុងប្រទេសដើម ចំពោះតែធាតុដែលមិនផ្លាស់ប្តូរលក្ខណៈញែកដាច់ពីគ្នា ហើយមិនប៉ះពាល់ដល់អត្តសញ្ញាណនៃម៉ាកក្នុងទម្រង់ដែលបានចុះបញ្ជីនៅក្នុងប្រទេសដើម។

**ឃ.-** គ្មានបុគ្គលណាមួយអាចទទួលផលប្រយោជន៍ពីបទប្បញ្ញត្តិនៃមាត្រានេះ ប្រសិនបើម៉ាកដែលបានអះអាងឱ្យការពារ មិនបានចុះបញ្ជីនៅក្នុងប្រទេសដើម។

**ង.-** ប៉ុន្តែ ការចុះបញ្ជីសារជាថ្មីនៃម៉ាកនៅក្នុងប្រទេសដើម មិនបង្កើតឱ្យមានកាតព្វកិច្ចក្នុងការចុះបញ្ជីសារជាថ្មី ក្នុងប្រទេសផ្សេងទៀតនៃសហភាព ដែលម៉ាកនោះបានចុះបញ្ជីនោះទេ។

**ច.-** ផលប្រយោជន៍នៃអាទិភាពត្រូវរក្សាមិនឱ្យប៉ះពាល់ ចំពោះសំណុំលិខិតស្នើសុំចុះបញ្ជីម៉ាកដែលបានដាក់នៅក្នុងរយៈពេលកំណត់នៃមាត្រា៤ ទោះបីបើការចុះបញ្ជីនៅក្នុងប្រទេសដើម ត្រូវធ្វើឡើងបន្ទាប់ពីការផុតរយៈពេលនេះក៏ដោយ។

## មាត្រា៦ ស្ទួន ៦

**[ ម៉ាកៈ សេវាសញ្ញា ]**

ប្រទេសទាំងឡាយនៃសហភាពត្រូវការពារសេវាសញ្ញា។ ប្រទេសទាំងនេះ មិនតម្រូវឱ្យចែងអំពីការចុះបញ្ជីសេវាសញ្ញាឡើយ។

## មាត្រា៦ ស្ទួន ៧

**[ ម៉ាកៈ ការចុះបញ្ជីដោយភ្នាក់ងារ ឬតំណាងនៃម្ចាស់ម៉ាកដោយគ្មានការអនុញ្ញាតពីម្ចាស់ម៉ាក ]**

១- ប្រសិនបើភ្នាក់ងារឬតំណាងម្ចាស់ម៉ាកនៃប្រទេសមួយរបស់សហភាព ស្នើសុំចុះបញ្ជីម៉ាកក្នុងនាមគាត់ផ្ទាល់នៅក្នុងប្រទេសមួយឬច្រើននៃសហភាព ដោយគ្មានការអនុញ្ញាតពីម្ចាស់ម៉ាក់ ម្ចាស់ម៉ាកមានសិទ្ធិជំទាស់នឹងការស្នើសុំចុះបញ្ជីឬអាចទាមទារឱ្យលុបចោល ឬលើកលែងតែ ភ្នាក់ងារ ឬតំណាងបានលើកហេតុផលការពារសកម្មភាពរបស់គាត់ ក្នុងការផ្ទេរសិទ្ធិដើម្បីជាប្រយោជន៍របស់ម្ចាស់ម៉ាកក្នុងការចុះបញ្ជី ប្រសិនបើច្បាប់នៃប្រទេសនោះអនុញ្ញាត។

២- លើកលែងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើ ម្ចាស់ម៉ាកមានសិទ្ធិជំទាស់ការប្រើប្រាស់ម៉ាកដោយភ្នាក់ងារ ឬតំណាងដោយគ្មានការអនុញ្ញាតឱ្យប្រើប្រាស់ពីម្ចាស់ម៉ាក។

៣- ច្បាប់ជាតិអាចបញ្ញត្តិអំពីរយៈពេលកំណត់សមស្របមួយ ដើម្បីឱ្យម្ចាស់ម៉ាកអនុវត្តសិទ្ធិដូចមានចែងក្នុងមាត្រានេះ។

## មាត្រា៧

### [ ម៉ាកៈ ប្រភេទនៃទំនិញដែលពាក់ម៉ាក ]

លក្ខណៈនៃទំនិញដែលម៉ាកត្រូវបំពាក់ មិនមែនជាឧបសគ្គក្នុងការចុះបញ្ជីម៉ាកទេ។

## មាត្រា៧ ស្ទួន

### [ ម៉ាកៈ ម៉ាកសមូហភាព ]

១- ប្រទេសទាំងឡាយនៃសហភាព សន្យាទទួលការដាក់ពាក្យសុំចុះបញ្ជី និងការពារម៉ាកសមូហភាព ដែលជាកម្មសិទ្ធិរបស់សមាគម ដែលបានបង្កើតមិនផ្ទុយទៅនឹងច្បាប់នៃប្រទេសដើម ទោះបីសមាគមនោះគ្មានគ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្មក៏ដោយ។

២- ប្រទេសនីមួយៗត្រូវកំណត់លក្ខខណ្ឌដោយឡែកដើម្បីការពារម៉ាកសមូហភាព ហើយអាចបដិសេធមិនការពារ ប្រសិនបើម៉ាកនោះផ្ទុយនឹងផលប្រយោជន៍សាធារណៈ។

៣- ម្យ៉ាងវិញទៀត កិច្ចការពារម៉ាកទាំងនេះមិនត្រូវបានបដិសេធចំពោះសមាគមណាមួយ ដែលបានបង្កើតមិនផ្ទុយទៅនឹងច្បាប់នៃប្រទេសដើម ដោយមូលហេតុថាសមាគមនេះមិនត្រូវបានបង្កើតឡើងក្នុងប្រទេសដែលសុំកិច្ចការពារ ឬ មិនត្រូវបានបង្កើតស្របតាមច្បាប់នៃប្រទេសដែលសុំកិច្ចការពារនោះ។

## មាត្រា៨

### [ ពាណិជ្ជនាម ]

ពាណិជ្ជនាមត្រូវការពារ ក្នុងគ្រប់ប្រទេសទាំងអស់នៃសហភាពដោយមិនតម្រូវឱ្យដាក់ពាក្យស្នើសុំ ឬចុះបញ្ជី ទោះជាពាណិជ្ជនាមនេះជាផ្នែក ឬ មិនមែនជាផ្នែកនៃម៉ាកក៏ដោយ។

## មាត្រា៩

**[ម៉ាក ពាណិជ្ជនាមៈ ការរឹបអូសទំនិញនាំចូល។ល។ ដែលពាក់ម៉ាកឬពាណិជ្ជនាមខុសច្បាប់]**

១- ទំនិញដែលពាក់ម៉ាកឬពាណិជ្ជនាមខុសច្បាប់ទាំងអស់ ត្រូវរឹបអូសពេលនាំចូលក្នុងប្រទេសនៃសហភាព ដែលការពារម៉ាកឬពាណិជ្ជនាមនោះ។

២- ការរឹបអូសត្រូវធ្វើផងដែរក្នុងប្រទេស ដែលមានពាក់ម៉ាកខុសច្បាប់ ឬ ក្នុងប្រទេសដែលនាំចូលទំនិញ។

៣- ការរឹបអូសត្រូវធ្វើឡើងតាមសំណើរបស់ព្រះរាជអាជ្ញា ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ឬភាគីមានប្រយោជន៍ ទោះជារូបវន្តបុគ្គលឬនីតិបុគ្គល ដោយអនុលោមតាមច្បាប់ជាតិនៃប្រទេសនីមួយៗ។

៤- អាជ្ញាធរមិនត្រូវរឹបអូស ទំនិញដែលឆ្លងកាត់ទេ។

៥- ប្រសិនបើច្បាប់នៃប្រទេសមួយមិនអនុញ្ញាតឱ្យរឹបអូសទំនិញដែលនាំចូល ការរឹបអូសត្រូវជំនួសដោយការហាមឃាត់ការនាំចូល ឬដោយការរឹបអូសខាងក្នុងប្រទេសវិញ។

៦- ប្រសិនបើច្បាប់នៃប្រទេសមួយមិនអនុញ្ញាត ការរឹបអូសលើការនាំចូល ការហាមឃាត់ការនាំចូល ឬការរឹបអូសខាងក្នុងប្រទេស រហូតដល់មានការកែប្រែច្បាប់ វិធានការទាំងនេះត្រូវជំនួសដោយ បណ្ដឹង និងវិធានការដោះស្រាយដែលច្បាប់នៃប្រទេសនោះបានធានាចំពោះពលរដ្ឋ។

## មាត្រា១០

**[ការចង្អុលបង្ហាញមិនត្រឹមត្រូវ : ការរឹបអូសការនាំចូល ។ល។ នូវទំនិញដែលចង្អុលបង្ហាញមិនត្រឹមត្រូវពីប្រភពដើម ឬអត្តសញ្ញាណរបស់ផលិតករ]**

១- បទប្បញ្ញត្តិនៃមាត្រាខាងលើ ត្រូវអនុវត្តក្នុងករណីនៃការប្រើប្រាស់ដោយផ្ទាល់ ឬដោយប្រយោលនៃការចង្អុលបង្ហាញមិនត្រឹមត្រូវពីប្រភពទំនិញ ឬអត្តសញ្ញាណនៃផលិតករ ឧស្សាហករ ឬពាណិជ្ជករ។

២- ផលិតករ ឧស្សាហករ ឬពាណិជ្ជករណាមួយ ទោះជារូបវន្តបុគ្គលឬនីតិបុគ្គលក្ដីដែលពាក់ព័ន្ធទៅនឹងផលិតកម្ម ឧស្សាហកម្ម ឬពាណិជ្ជកម្មនូវទំនិញទាំងនោះ ហើយបង្កើតជាការចង្អុលបង្ហាញមិនត្រឹមត្រូវពីប្រភព នៅក្នុងទីតាំង ឬក្នុងតំបន់នៃទីតាំង ឬក្នុងប្រទេសដែលមានការចង្អុលបង្ហាញមិនត្រឹមត្រូវពីប្រភព ឬក្នុងប្រទេសដែលមានការប្រើប្រាស់ការចង្អុលបង្ហាញមិនត្រឹមត្រូវពីប្រភព ក្នុងករណីទាំងនេះ ត្រូវចាត់ទុកជាភាគីមានប្រយោជន៍។

## មាត្រា១០ ស្ទួន

**[ការប្រកួតប្រជែងមិនស្មោះត្រង់]**

១- ប្រទេសទាំងឡាយនៃសហភាព ត្រូវធានាឱ្យពលរដ្ឋរបស់ខ្លួននូវកិច្ចការពារប្រកបដោយប្រសិទ្ធិភាពប្រឆាំងនឹងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

២- អំពើនៃការប្រកួតប្រជែងណា ដែលផ្ទុយពីការអនុវត្តទៀងត្រង់នៅក្នុងវិស័យឧស្សាហកម្មឬពាណិជ្ជកម្ម ត្រូវចាត់ទុកជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

៣- ទង្វើទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់:

(១) អំពើទាំងឡាយ ដែលបង្កើតឱ្យមានការភ័ន្តច្រឡំ តាមមធ្យោបាយណាមួយជាមួយសហគ្រាសពាណិជ្ជកម្ម ជាមួយទំនិញ ឬ ជាមួយសកម្មភាពឧស្សាហកម្ម ឬពាណិជ្ជកម្ម នៃគូរប្រកួតប្រជែង។

(២) ការពោលអះអាងមិនត្រឹមត្រូវ ក្នុងពាណិជ្ជកម្មដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះសហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្មឬពាណិជ្ជកម្មនៃគូរប្រកួតប្រជែង។

(៣) ការបញ្ជាក់ឬការពោលអះអាង ដែលបានប្រើប្រាស់ក្នុងពាណិជ្ជកម្មដែលអាចធ្វើឱ្យសាធារណៈជនភ័ន្តច្រឡំអំពី ប្រភេទ ដំណើរការផលិត លក្ខណៈ ភាពសមស្របសម្រាប់គោលបំណង ឬបរិមាណ នៃទំនិញ។

## មាត្រា១០ ស្ទួន ៣

## [ ម៉ាក ពាណិជ្ជនាម ការចង្អុលបង្ហាញមិនត្រឹមត្រូវ ការប្រកួតប្រជែងមិនស្មោះត្រង់: វិធានការដោះស្រាយ សិទ្ធិប្ដឹង ]

១- ប្រទេសទាំងឡាយនៃសហភាព ត្រូវសន្យាធានា ឱ្យពលរដ្ឋរបស់ប្រទេសផ្សេងៗទៀតនៃសហភាព នូវវិធានការដោះស្រាយសមស្របតាមផ្លូវច្បាប់ឱ្យមានប្រសិទ្ធភាព ដើម្បីបង្ក្រាបនូវអំពើទាំងឡាយដូចមានចែងក្នុងមាត្រា៩ មាត្រា១០ និងមាត្រា១០ស្ទួន។

២- ប្រទេសទាំងឡាយនៃសហភាព ត្រូវសន្យា បង្កើតវិធានការដែលអនុញ្ញាតឱ្យសហព័ន្ធនិងសមាគមដែលតំណាងឱ្យឧស្សាហករ ផលិតករ ឬ ពាណិជ្ជករដែលមានផលប្រយោជន៍ ឱ្យតែការបង្កើតសហព័ន្ធនិងសមាគមទាំងនេះមិនផ្ទុយនឹងច្បាប់នៃប្រទេសនោះ ដើម្បីចាត់វិធានការតាមផ្លូវតុលាការ ឬចំពោះមុខអាជ្ញាធររដ្ឋបាល ក្នុងគោលបំណងបង្ក្រាបអំពើទាំងឡាយដូចមានចែងក្នុងមាត្រា៩ មាត្រា១០ និងមាត្រា១០ស្ទួន ក្នុងលក្ខខណ្ឌដែលច្បាប់នៃប្រទេសដែលអះអាងឱ្យការពារនោះ អនុញ្ញាតឱ្យធ្វើបែបនេះចំពោះសហព័ន្ធនិងសមាគមនៃប្រទេសនោះ។

## មាត្រា១១

## [ តក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ម៉ាក: កិច្ចការពារបណ្ដោះអាសន្នក្នុងពិពណ៌អន្តរជាតិមួយចំនួន ]

១- ដោយអនុលោមតាមច្បាប់ជាតិ ប្រទេសទាំងឡាយនៃសហភាពត្រូវការពារជាបណ្ដោះអាសន្នចំពោះតក្កកម្មដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម និងម៉ាក ចំពោះទំនិញដែលដាក់តាំងជាផ្លូវការ ឬ ក្នុងពិពណ៌អន្តរជាតិដែលទទួលស្គាល់ជាផ្លូវការ ដែលធ្វើឡើងក្នុងដែនដីណាមួយនៃប្រទេសទាំងនេះ។

២- កិច្ចការពារជាបណ្ដោះអាសន្ននេះ មិនពន្យាររយៈពេល ដូចមានចែងក្នុងមាត្រា៤ទេ។ ក្រោយមក ប្រសិនបើ មានការអះអាងអំពីសិទ្ធិអាទិភាព អាជ្ញាធរនៃប្រទេសណាមួយអាចចែងថា រយៈពេលនេះត្រូវចាប់ផ្ដើមពីកាលបរិច្ឆេទនៃការបង្ហាញទំនិញក្នុងពិពណ៌។

៣- ដើម្បីជាភស្តុតាងនៃអត្តសញ្ញាណរបស់ទំនិញ ដែលដាក់តាំងនិងជាភស្តុតាងនៃកាលបរិច្ឆេទការបង្ហាញទំនិញ ប្រទេសនីមួយៗអាចតម្រូវឱ្យមានឯកសារជាភស្តុតាងនានាបើយល់ថាចាំបាច់។

## មាត្រា១២

## [ សេវាកម្មជាតិពិសេសចំពោះកម្មសិទ្ធិឧស្សាហកម្ម ]

១-ប្រទេសនីមួយៗនៃសហភាព សន្យាបង្កើតឱ្យមានសេវាកម្មពិសេស ចំពោះកម្មសិទ្ធិឧស្សាហកម្ម និងការិយាល័យកណ្ដាលមួយ ដើម្បីទាក់ទងជាមួយ សាធារណៈជនចំពោះប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម និងម៉ាក។

២- សេវាកម្មនេះត្រូវបោះពុម្ពផ្សាយជាព្រឹត្តិប័ត្រផ្លូវការ ហើយឱ្យទៀងទាត់:

ក- ឈ្មោះម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងការបង្ហាញដោយសង្ខេបនៃតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្ម។

ខ- ការផលិតឡើងវិញនៃម៉ាកដែលបានចុះបញ្ជី។

## មាត្រា១៣

## [ សន្និបាតនៃសហភាព ]

១-

ក- សហភាពត្រូវមានសន្និបាតមួយ ដែលរួមមានប្រទេសនៃសហភាពដែលកំណត់ក្នុងមាត្រា១៣ ដល់មាត្រា១៧។

ខ- រដ្ឋាភិបាលនៃប្រទេសនីមួយៗត្រូវតំណាងដោយប្រតិភូមួយរូប ដែលអាចអមដោយប្រតិភូស្ដីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន។

គ- ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនេះ។

២-

ក- សន្និបាតត្រូវ:

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សានិងការអភិវឌ្ឍន៍នៃសហភាព និងការអនុវត្តន៍អនុសញ្ញានេះ

(ii) ណែនាំអំពីការរៀបចំសន្និសីទកែប្រែ ជូនការិយាល័យអន្តរ-ជាតិកម្មសិទ្ធិបញ្ញា(តទៅហៅថា"ការិយាល័យអន្តរជាតិ") ដែលបានកំណត់ក្នុងអនុសញ្ញាស្តីពីការបង្កើតអង្គការកម្មសិទ្ធិ បញ្ញាពិភពលោក ( តទៅហៅថា "អង្គការ" ) ដោយពិចារណាលើមតិយោបល់នៃប្រទេសក្នុងសហភាព ដែលមិនជាប់កាតព្វកិច្ចតាមមាត្រា១៣ ដល់ មាត្រា១៧

(iii) ត្រួតពិនិត្យ និងអនុម័តរបាយការណ៍ និងសកម្មភាពដែលទាក់ទងនឹងសហភាពនៃអគ្គនាយករបស់អង្គការ ហើយណែនាំតាមការចាំបាច់ដល់អគ្គនាយកដែលទាក់ទងនឹងបញ្ហានៃសមត្ថកិច្ចរបស់សហភាព

(iv) បោះឆ្នោតជ្រើសរើសសមាជិកនៃគណៈកម្មាធិការប្រតិបត្តិរបស់សន្និបាទ

(v) ពិនិត្យនិងអនុម័តរបាយការណ៍ និងសកម្មភាពរបស់គណៈកម្មាធិ-ការប្រតិបត្តិ ហើយផ្តល់ការណែនាំដល់គណៈកម្មាធិការនេះ

(vi) កំណត់កម្មវិធី អនុម័តថវិកាពីរឆ្នាំម្តងនៃសហភាព និងអនុម័តការបិទបញ្ជីគណនី

(vii) អនុម័តបទបញ្ញាស្តីពីហិរញ្ញវត្ថុរបស់សហភាព

(viii) បង្កើតគណៈកម្មាធិការជំនាញនិងក្រុមការងារដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់សហភាព

(ix) កំណត់ឱ្យចូលរួមក្នុងកិច្ចប្រជុំ ក្នុងឋានៈជាអ្នកសង្កេតការណ៍ចំពោះប្រទេសដែលមិនមែនជាសមាជិកនៃសហភាព និងអង្គការអន្តររដ្ឋាភិបាលនិងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល

(x) អនុម័តវិសោធនកម្មមាត្រា១៣ ដល់ មាត្រា១៧

(xi) ចាត់វិធានការសមស្របផ្សេងទៀតដើម្បីសម្រេចគោលបំណងរបស់សហភាព

(xii) បំពេញមុខងារផ្សេងទៀតដែលស្របតាមអនុសញ្ញានេះ

(xiii) អនុវត្តសិទ្ធិ ដែលប្រគល់ឱ្យដោយអនុសញ្ញាស្តីពីការបង្កើតអង្គការ បើសន្និបាតយល់ព្រម។

ខ- ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាតត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

៣-

ក- លើកលែងបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ) ប្រតិភូម្នាក់អាចជាតំណាងឱ្យប្រទេសមួយតែប៉ុណ្ណោះ។

ខ- ប្រទេសទាំងឡាយនៃសហភាពដែលត្រូវបានបង្កើតជាក្រុមក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពិសេស នៅក្នុងការិយាល័យរួមមួយដែលមានចារិកលក្ខណៈជាសេវាជាតិកម្មសិទ្ធិឧស្សាហកម្មពិសេស ដូចមានចែងក្នុងមាត្រា១២ អាចតំណាងរួមគ្នាដោយប្រទេសតែមួយ ក្នុងពេលពិភាក្សា ។

៤-

ក- ប្រទេសនីមួយៗជាសមាជិកនៃសន្និបាតមានសំលេងឆ្នោតតែមួយ។

ខ- កូរ៉ុមនៃសន្និបាតត្រូវមានចំនួនពាក់កណ្តាលនៃប្រទេសជាសមាជិក។

គ- លើកលែងតែបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ) ក្នុងសម័យប្រជុំនីមួយៗ ប្រសិនបើចំនួនប្រទេសតំណាងមានតិចជាង ១/២(មួយភាគពីរ) ប៉ុន្តែស្មើឬច្រើនជាង១/៣(មួយភាគបី)នៃប្រទេសជាសមាជិកទាំងឡាយនៃសន្និបាត សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះ ត្រូវយកមកអនុវត្តបាន តែក្នុងករណីបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែងតែសេចក្តីសម្រេចនោះទាក់ទងនឹងនីតិវិធីរបស់សន្និបាត។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ទៅប្រទេសសមាជិកសន្និបាទទាំងឡាយដែលអវត្តមាន និងត្រូវអញ្ជើញប្រទេសទាំងនេះ ឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេល៣(បី)ខែចាប់ពីថ្ងៃជូនដំណឹង។ បើផុតរយៈពេលនេះ ប្រសិនបើ ចំនួននៃប្រទេសដែលបានបោះឆ្នោតឬបោះឆ្នោតអនុប្បវាទស្មើនឹងចំនួនប្រទេសដែលខ្វះ សម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្តីសម្រេចនេះនឹងអាចយកមកអនុវត្តបាន ឱ្យតែបានគ្រប់សំលេងភាគច្រើនដែលត្រូវការ ។

ឃ- លើកលែងតែបទប្បញ្ញត្តិនៃមាត្រា១៧(២) សេចក្តីសម្រេចនៃសន្និបាតត្រូវធ្វើឡើងដោយសំលេងភាគច្រើន២/៣(ពីរភាគបី)នៃសំលេងឆ្នោតដែលបានបោះ។

ង- អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

៥-

ក- លើកលែងបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ខ) ប្រតិភូម្នាក់អាចបោះឆ្នោតបានក្នុងនាមប្រទេសតែមួយគត់។

ខ- ប្រទេសទាំងឡាយនៃសហភាពដូចដែលមានចែងក្នុងកថាខណ្ឌ៣(ខ) ជាវិធានទូទៅ ត្រូវខិតខំបញ្ជូនគណៈប្រតិភូផ្ទាល់របស់ខ្លួនទៅចូលរួមប្រជុំសន្និបាត។ ប៉ុន្តែក្នុងករណីពិសេស បើប្រទេសណាមួយនេះមិនអាចបញ្ជូនគណៈប្រតិភូផ្ទាល់របស់ខ្លួនបានទេ ប្រទេសនេះ អាចប្រគល់អំណាចបោះឆ្នោតក្នុងនាមខ្លួនឱ្យគណៈប្រតិភូនៃប្រទេសដទៃ ឱ្យតែគណៈប្រតិភូនីមួយៗអាចបោះឆ្នោតជាតំណាងនៃប្រទេសតែមួយ។ អំណាចបោះឆ្នោតនេះត្រូវបានធ្វើជាលិខិតដែលចុះហត្ថលេខាដោយប្រមុខរដ្ឋ ឬរដ្ឋមន្ត្រីដែលមានសមត្ថកិច្ច។

៦- ប្រទេសទាំងឡាយនៃសហភាពដែលមិនមែនជាសមាជិកសន្និបាតត្រូវអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍។

៧-

ក- សន្និបាតត្រូវប្រជុំជាសាមញ្ញរៀងរាល់ ២(ពីរ)ឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេស ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ។

ខ- តាមសំណើសុំពីគណៈកម្មាធិការប្រតិបត្តិ ឬពីប្រទេសជាសមាជិកសន្និបាតចំនួន ១/៤(មួយភាគបួន) សន្និបាតត្រូវប្រជុំជាវិសាមញ្ញបាន តាមការកោះប្រជុំរបស់អគ្គនាយក ។

៨- សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា១៤

### [ គណៈកម្មាធិការប្រតិបត្តិ ]

១- សន្និបាតត្រូវមានគណៈកម្មាធិការប្រតិបត្តិមួយ។

២-

ក- គណៈកម្មាធិការប្រតិបត្តិ មានសមាជិកជាប្រទេសដែលបានជ្រើសរើសដោយសន្និបាត ក្នុងចំណោមប្រទេសជាសមាជិកទាំងឡាយនៃសន្និបាត។ ប្រទេសដែលតាំងទីស្នាក់ការរបស់អង្គការ លើកលែងតែបទប្បញ្ញត្តិមាត្រា១៦(៧)(ខ) ត្រូវមាន អាសនៈមួយជាស្វ័យប្រវត្តិក្នុងគណៈកម្មាធិការនេះ។

ខ- រដ្ឋាភិបាលនៃប្រទេសនីមួយៗត្រូវតំណាងដោយប្រតិភូមួយរូប ដែលអាច

អមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន។

គ- ការចំណាយរបស់គណៈប្រតិភូនីមួយៗ ជាបន្ទុករបស់រដ្ឋាភិបាលដែលតែងតាំងគណៈប្រតិភូនេះ។

៣- ចំនួនប្រទេសជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិត្រូវស្មើនឹងចំនួន១/៤ (មួយភាគបួន)នៃចំនួនប្រទេសជាសមាជិកសន្និបាត។ ក្នុងការកំណត់ចំនួនអាសនៈ អាសនៈដែលនៅសល់ពីការបែងចែកជា៤(បួន)ហើយ មិនត្រូវយកមកពិចារណាទេ។

៤- ក្នុងការជ្រើសរើសសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ សន្និបាតត្រូវពិចារណាលើការបែងចែកតាមភូមិសាស្ត្រឱ្យសមធម៌ និងពិចារណាលើភាពចាំបាច់នៃប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀងពិសេសដែលមានទំនាក់ទំនងជាមួយសហភាព ដើម្បីឱ្យក្លាយជាប្រទេសដែលបង្កើតគណៈកម្មាធិការប្រតិបត្តិផងដែរ។

៥-

ក- សមាជិកនីមួយៗនៃគណៈកម្មាធិការប្រតិបត្តិត្រូវចូលបំរើការចាប់ពីពេលបិទសម័យប្រជុំសន្និបាតដែលបានជ្រើសរើសខ្លួន រហូតដល់ពេលបិទប្រជុំសាមញ្ញលើកក្រោយនៃសន្និបាត។

ខ- សមាជិកនៃគណៈកម្មាធិការប្រតិបត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតសារជាថ្មីបាន ប៉ុន្តែមិនអាចលើសពី២/៣(ពីរភាគបី)នៃសមាជិកគណៈកម្មាធិកាប្រតិបត្តិឡើយ។

គ- សន្និបាតត្រូវបង្កើតបែបបទលម្អិតនៃបោះឆ្នោតនិងបែបបទនៃការបោះឆ្នោតសារជាថ្មីនៃសមាជិកគណៈកម្មាធិការប្រតិបត្តិ។

៦-

ក- គណៈកម្មាធិការប្រតិបត្តិត្រូវៈ

(i) រៀបចំសេចក្តីព្រាងរបៀបវារៈរបស់សន្និបាត

(ii) ដាក់ជូនសន្និបាតនូវសំណើដែលទាក់ទងនឹងទៅសេចក្តីព្រាងកម្មវិធីនិងថវិកា២(ពីរ)ឆ្នាំម្តងរបស់សហភាព ដែលរៀបចំដោយអគ្គនាយក

(iii) [ លុបចោល ]

(iv) ដាក់ជូនសន្និបាត រួមជាមួយយោបល់ នូវរបាយការណ៍ របស់អគ្គនាយក និងរបាយការណ៍សវនកម្មគណនីប្រចាំឆ្នាំ

(v) ចាត់វិធានការចាំបាច់ដើម្បីធានាការអនុវត្តន៍កម្មវិធីរបស់សហភាពតាមរយៈអគ្គនាយក ដោយយោងតាមសេចក្តីសម្រេចរបស់

សន្និបាត និងយោងតាមកាលៈទេសៈដែលកើតមានឡើង ចន្លោះសម័យប្រជុំសាមញ្ញទាំងពីររបស់សន្និបាត។

(vi) អនុវត្តតួនាទីផ្សេងៗទៀតដែលបានផ្តល់ឱ្យដោយអនុសញ្ញានេះ។

ខ- ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ គណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

៧-

ក- គណៈកម្មាធិការប្រតិបត្តិ ត្រូវប្រជុំជាសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើអាចធ្វើទៅបាន ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងគណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

ខ- តាមគំនិតផ្តួចផ្តើមរបស់គណៈកម្មាធិការប្រតិបត្តិ ឬតាមសំណើរបស់នាយក ឬរបស់សមាជិក១/៤(មួយភាគបួន) គណៈកម្មាធិការប្រតិបត្តិ ត្រូវប្រជុំជាវិសាមញ្ញបាន តាមការកោះប្រជុំរបស់អគ្គនាយក ។

៨-

ក- ប្រទេសនីមួយៗជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិមានសំលេងឆ្នោតតែមួយ។

ខ- កូរ៉ុមនៃគណៈកម្មាធិការប្រតិបត្តិ ត្រូវមានចំនួនពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការប្រតិបត្តិ។

គ- សេចក្តីសម្រេចត្រូវធ្វើឡើងដោយសំលេងភាគច្រើនធម្មតានៃសំលេងឆ្នោតដែលបានបោះ។

ឃ- អនុប្បវាទមិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ។

ង- ប្រតិភូម្នាក់អាចតំណាង ហើយបោះឆ្នោតបានក្នុងនាមប្រទេសតែមួយគត់។

៩- ប្រទេសទាំងឡាយនៃសហភាពដែលមិនមែនជាសមាជិកគណៈកម្មាធិការប្រតិបត្តិត្រូវអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍។

១០- គណៈកម្មាធិការប្រតិបត្តិត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## មាត្រា១៥

## [ ការិយាល័យអន្តរជាតិ ]

១-

ក- ការងាររដ្ឋបាលរបស់សហភាពត្រូវបំពេញដោយការិយាល័យអន្តរជាតិដែលបន្តពីការិយាល័យសហភាព រួមបញ្ចូលជាមួយការិយាល័យសហភាពដែលត្រូវបានបង្កើតដោយអនុសញ្ញាអន្តរជាតិស្តីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ។

ខ- ជាពិសេស ការិយាល័យអន្តរជាតិត្រូវបំរើការងារជាលេខាធិការដ្ឋានសម្រាប់អង្គភាពនានានៃសហភាព។

គ- អគ្គនាយកនៃអង្គការត្រូវជានាយកប្រតិបត្តិនៃសហភាពនិងជាតំណាងសហភាព។

២- ការិយាល័យអន្តរជាតិមាននាទីប្រមូលផ្តុំនិងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងកិច្ចការកម្មសិទ្ធិឧស្សាហកម្ម។ ប្រទេសនីមួយៗនៃសហភាពត្រូវធ្វើទំនាក់ទំនងភ្លាមទៅការិយាល័យអន្តរជាតិនូវរាល់ច្បាប់ថ្មី និងអត្ថបទផ្លូវការទាំងឡាយទាក់ទងនឹងកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម។ ជាងនេះទៅទៀត ប្រទេសនីមួយៗត្រូវផ្តល់ដល់ការិយាល័យអន្តរជាតិនូវរាល់ការបោះពុម្ពផ្សាយនៃសេវាកម្មកម្មសិទ្ធិឧស្សាហកម្មរបស់ខ្លួន ដែលពាក់ព័ន្ធផ្ទាល់ដល់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ដែលការិយាល័យអន្តរជាតិគិតថាមានសារៈសំខាន់ចំពោះការងាររបស់ខ្លួន។

៣- ការិយាល័យអន្តរជាតិត្រូវធ្វើការបោះពុម្ពផ្សាយជាប្រចាំខែ។

៤- បើមានការស្នើសុំ ការិយាល័យអន្តរជាតិ ត្រូវផ្តល់ដល់ប្រទេសណាមួយនៃសហភាពនូវព័ត៌មានស្តីពីបញ្ហាពាក់ព័ន្ធនឹងកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម។

៥- ការិយាល័យអន្តរជាតិត្រូវធ្វើការសិក្សានិងត្រូវផ្តល់សេវាកម្មដើម្បីជួយសម្រួលដល់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម។

៦- អគ្គនាយក និងបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយកត្រូវចូលរួមរាល់កិច្ចប្រជុំសន្និបាត គណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការជំនាញនិងក្រុមការងារផ្សេងៗទៀត តែគ្មានសិទ្ធិបោះឆ្នោតទេ។ អគ្គនាយក ឬបុគ្គលិកណាម្នាក់ដែលត្រូវចាត់តាំងដោយអគ្គនាយក គឺជាលេខាដោយស្វ័យប្រវត្តិរបស់អង្គភាពទាំងនេះ។

៧-

ក- តាមសេចក្តីណែនាំរបស់សន្និបាត និងដោយមានកិច្ចសហការប្រតិបត្តិការជាមួយគណៈកម្មាធិការប្រតិបត្តិ ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែបទប្បញ្ញត្តិនៃអនុសញ្ញា លើកលែងតែមាត្រា១៣ ដល់ មាត្រា១៧។

ខ- ការិយាល័យអន្តរជាតិអាចប្រឹក្សាជាមួយអង្គការអន្តររដ្ឋាភិបាលនិងអង្គ-អន្តរជាតិមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ។

គ-អគ្គនាយកនិងបុគ្គលដែលត្រូវចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទទាំងនោះ តែគ្មានសិទ្ធិបោះឆ្នោតទេ។

៨- ការិយាល័យអន្តរជាតិត្រូវអនុវត្តការងារផ្សេងៗទៀតដែលប្រគល់ឱ្យ។

## មាត្រា១៦

## [ហិរញ្ញវត្ថុ]

១-

ក- សហភាពត្រូវមានថវិការបស់ខ្លួន។

ខ- ថវិការបស់សហភាពរួមមានខ្ទង់ចំនូលនិងខ្ទង់ចំណាយផ្ទាល់របស់សហ-ភាព វិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាព និងបើមាន ចំនួនទឹកប្រាក់ត្រូវប្រើសម្រាប់សន្និសីទរបស់អង្គការ។

គ- ការចំណាយដែលមិនមែនជាចំណាយផ្តាច់មុខរបស់សហភាពប៉ុន្តែជាការចំណាយរបស់សហភាពមួយឬច្រើនផ្សេងទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការត្រូវចាត់ទុកជាចំណាយរួមរបស់សហភាព។ ចំណែកនៃសហភាពក្នុងខ្ទង់ចំណាយរួមនេះត្រូវសមាមាត្រនឹងផលប្រយោជន៍ដែលសហភាពទទួលបានក្នុងចំណាយនោះ។

២- ថវិការបស់សហភាពត្រូវបង្កើតឡើយ ដោយផ្អែកលើតម្រូវការសម្របសម្រួលជាមួយថវិកានៃសហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ។

៣- ថវិការបស់សហភាពទទួលបានពីប្រភពនានាដូចខាងក្រោម:

(i) វិភាគទានពីប្រទេសនៃសហភាព

(ii) កម្រៃនិងថ្លៃឈ្នួលសេវាកម្ម ដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិក្នុងនាមសហភាព

(iii) ការលក់ ឬលាភការ ពីការបោះពុម្ពផ្សាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាព

(iv) អំណោយ អច្ច័យទាន និងឧបត្ថម្ភធន

(v) ការជួល ការប្រាក់ និងចំណូលផ្សេងៗទៀត។

៤-

ក- ដើម្បីបង្កើតជាវិភាគទាននៃថវិកា ប្រទេសនីមួយៗនៃសហភាព ត្រូវចាត់ជាចំណាត់ថ្នាក់ ហើយត្រូវបង់វិភាគទានប្រចាំឆ្នាំផ្អែកលើចំនួនឯកតានៃចំណាត់ថ្នាក់កំណត់

ដូចខាងក្រោម:		ថ្នាក់ទី I ..........................២៥

ថ្នាក់ទី II ..........................២០

ថ្នាក់ទី III .......................១៥

ថ្នាក់ទី IV .......................១០

ថ្នាក់ទី V ..........................៥

ថ្នាក់ទី VI .........................៣

ថ្នាក់ទី VII........................១

ខ- លើកលែងតែបានធ្វើចំណាត់ថ្នាក់រួចហើយ ប្រទេសនីមួយៗ ត្រូវបញ្ជាក់ពីចំណាត់ថ្នាក់ដែលគេចង់បាន នៅពេលតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ។ ប្រទេសនីមួយៗអាចប្តូរចំណាត់ថ្នាក់បាន។ ប្រសិនបើប្រទេសណាមួយជ្រើសរើសចំណាត់ថ្នាក់ទាប ប្រទេសនោះ ត្រូវប្រកាសពីការផ្លាស់ប្តូរនេះក្នុងសម័យប្រជុំសាមញ្ញណាមួយនៃសន្និបាត។ ការផ្លាស់ប្តូរណាមួយនឹងមានសុពលភាពនៅដើមឆ្នាំប្រក្រតីទិនបន្ទាប់ពីកិច្ចប្រជុំ។

គ- វិភាគទានប្រចាំឆ្នាំនៃប្រទេសនីមួយៗ ត្រូវមានចំនួនសមាមាត្រគ្នានឹងចំនួនសរុប ដែលបានធ្វើវិភាគទានទៅថវិការបស់សហភាពដោយប្រទេសទាំងអស់ដូចនឹងចំនួនឯកតារបស់ខ្លួនទៅចំនួនសរុបនៃឯកតានៃប្រទេសផ្តល់វិភាគទានទាំងអស់។

ឃ- ការបង់វិភាគទានត្រូវធ្វើឡើងនៅថ្ងៃទី ១ ខែ មករា ជារៀងរាល់ឆ្នាំ។

ង- ប្រទេសដែលយឺតយ៉ាវក្នុងការបង់វិភាគទាន មិនអាចអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួនក្នុងអង្គភាពនៃសហភាពដែលខ្លួនជាសមាជិក ប្រសិនបើចំនួនដែលមិនបានបង់មានចំនួនស្មើ ឬលើសពីចំនួននៃវិភាគទានត្រូវបង់ចំនួន២(ពីរ)ឆ្នាំពេញ។ ប៉ុន្តែ អង្គភាពណាមួយនៃសហភាព អាចអនុញ្ញាតឱ្យប្រទេសដែលយឺតយ៉ាវអាចបន្តអនុវត្តសិទ្ធិបោះឆ្នោតក្នុងអង្គភាពនោះបាន ដរាបណាបានផ្តល់ហេតុផលត្រឹមត្រូវពីការយឺតយ៉ាវក្នុងការបង់វិភាគទាន ដោយកាលៈទេសៈពិសេស និងមិនអាចជៀសវាងបាន។

ច- ប្រសិនបើថវិកាមិនត្រូវបានអនុម័តមុនការចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មីទេ ថវិកានោះ ត្រូវតែចាត់ទុកថាមានកម្រិតស្មើគ្នាទៅនឹងថវិកាឆ្នាំមុន ដូចមានចែងក្នុងបទបញ្ជាហិរញ្ញវត្ថុ។

៥- បរិមាណនៃកម្រៃនិងថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិក្នុងនាមសហភាពនឹងត្រូវកំណត់ នឹងត្រូវរាយការណ៍ទៅសន្និបាត និងគណៈកម្មាធិការ-ប្រតិបត្តិដោយអគ្គនាយក។

៦-

ក- សហភាពត្រូវមានមូលនិធិទុនបង្វិលដែលទទួលបានពីការបង់ប្រាក់សរុបរួមតែមួយពីប្រទេសនីមួយៗនៃសហភាព។ ប្រសិនបើមូលនិធិនេះមិនគ្រប់គ្រាន់ សន្និបាតអាចសម្រេចបង្កើនមូលនិធិនេះបាន។

ខ- ចំនួននៃការបង់ប្រាក់ដំបូងរបស់ប្រទេសនីមួយៗក្នុងមូលនិធិនេះ ឬនៃការចូលរួមរបស់ខ្លួនក្នុងការបង្កើនមូលនិធិ ត្រូវសមាមាត្រនឹងវិភាគទាននៃប្រទេសនោះសម្រាប់ឆ្នាំនៃការបង្កើតមូលនិធិនេះ ឬឆ្នាំនៃការសម្រេចបង្កើនមូលនិធិ។

គ- សមាមាត្រ និងលក្ខខណ្ឌនៃការបង់ប្រាក់ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក និងបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ។

៧-

ក- នៅក្នុងកិច្ចព្រមព្រៀងទីស្នាក់ការ ដែលបានចុះជាមួយប្រទេសដែលអង្គការដាក់ទីស្នាក់ការនៅលើទឹកដីប្រទេសនោះ ត្រូវចែងថានៅពេលណាដែលមូលនិធិទុនបង្វិលមិនគ្រប់គ្រាន់ ប្រទេសនោះត្រូវបង់ប្រាក់ជាមុន។ ចំនួននៃប្រាក់បង់ជាមុននិងលក្ខខណ្ឌនៃការបង់ជាមុន ត្រូវកំណត់ដោយកិច្ចព្រមព្រៀងដោយឡែកពីគ្នារវាងប្រទេសនោះជាមួយអង្គការ។ ដរាបណាប្រទេសនោះនៅតែមានកាតព្វកិច្ចបង់ប្រាក់ជាមុន ប្រទេសនោះត្រូវមានអាសនៈជាស្វ័យប្រវត្តិក្នុងគណៈកម្មាធិការប្រតិបត្តិ។

ខ- ប្រទេសដូចមានចែងក្នុងអនុកថាខណ្ឌ(ក) និងអង្គការ ត្រូវមានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការបដិសេធនេះ ត្រូវមានអានុភាពក្នុងរយៈពេល៣(បី)ឆ្នាំបន្ទាប់ពីបំណាច់ឆ្នាំនៃការជូនដំណឹង។

៨- សវនកម្មគណនី ត្រូវធ្វើឡើងដោយប្រទេសមួយឬច្រើននៃសហភាព ឬដោយសវនករខាងក្រៅ ដូចមានចែងក្នុងបទបញ្ជាហិរញ្ញវត្ថុ ហើយត្រូវចាត់តាំងដោយសន្និបាតដោយមានការយល់ព្រមពីប្រទេសឬសវនករនេះ។

## មាត្រា១៧

## [ វិសោធនកម្មមាត្រា១៣ ដល់មាត្រា១៧ ]

១- សំណើសុំវិសោធនកម្មមាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៦ និងមាត្រានេះអាចត្រូវផ្តួចផ្តើមគំនិតដោយប្រទេសសមាជិកណាមួយនៃសន្និបាត ដោយគណៈកម្មាធិការប្រតិបត្តិ ឬដោយអគ្គនាយក។ សំណើនេះត្រូវជូនដំណឹងទៅឱ្យប្រទេសជាសមាជិកសន្និបាត ដោយអគ្គនាយកយ៉ាងហោចណាស់រយៈពេល៦(ប្រាំមួយ)ខែមុនពេលសន្និបាតលើកសំណើនេះមកពិចារណា។

២- វិសោធនកម្មមាត្រាដូចមានចែងក្នុងកថាខណ្ឌទី១ ត្រូវអនុម័តដោយសន្និបាត។ ការអនុម័តនេះទាមទារឱ្យមានសំលេងឆ្នោត ៣/៤ (បីភាគបួន) តែវិសោធនកម្មមាត្រា១៣ និងកថាខណ្ឌនេះ ទាមទារឱ្យមានសំលេងឆ្នោត ៤/៥ (បួនភាគប្រាំ)។

៣- វិសោធនកម្មណាមួយចំពោះមាត្រាក្នុងកថាខណ្ឌ១ ត្រូវចូលជាធរមានក្នុងរយៈពេល១(មួយ)ខែ ក្រោយពីអគ្គនាយកទទួលបានសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលបានធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ ដោយប្រទេស ៣/៤ (បីភាគបួន)ដែលជាសមាជិកសន្និបាតហើយមានវត្តមាននៅពេលអនុម័តវិសោធនកម្មនេះ។ វិសោធនកម្មមាត្រាទាំងនេះ ហើយដែលត្រូវបានទទួលយក មានអានុភាពចងប្រទេសទាំងឡាយដែលជាសមាជិកសន្និ-បាត នៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមានឬ ក្លាយជាសមាជិកនាពេលក្រោយ។ វិសោធនកម្មណាដែលបង្កើនកាតព្វកិច្ចហិរញ្ញវត្ថុរបស់ប្រទេសនៃសហភាពមានអានុភាពចងតែប្រទេសណាដែលប្រកាសយល់ព្រមវិសោធនកម្មនេះប៉ុណ្ណោះ។

## មាត្រា១៨

## [ ការកែប្រែមាត្រា១ ដល់ មាត្រា១២ និង មាត្រា ១៨ ដល់ មាត្រា៣០ ]

១- អនុសញ្ញានេះនឹងដាក់ឱ្យកែប្រែ ដើម្បីឱ្យប្រព័ន្ធនៃសហភាពមានលក្ខណៈកាន់តែប្រសើរឡើង។

២- សម្រាប់គោលបំណងនេះ សន្និសីទត្រូវប្រារព្ធធ្វើជាបន្តបន្ទាប់ក្នុងប្រទេសមួយនៃបណ្ដាប្រទេសក្នុងសហភាព ដោយប្រតិភូនៃប្រទេសទាំងនេះ។

៣- វិសោធនកម្មមាត្រា១៣ ដល់ មាត្រា១៧ ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃមាត្រា១៧។

## មាត្រា១៩

## [ កិច្ចព្រមព្រៀងពិសេស ]

ប្រទេសទាំងឡាយនៃសហភាព រក្សាសិទ្ធិបង្កើតកិច្ចព្រមព្រៀងពិសេសដោយឡែករវាងគ្នា ស្ដីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ឱ្យតែកិច្ចព្រមព្រៀងទាំងនេះមិនផ្ទុយនឹងបទ-ប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា២០

## [ ការផ្ដល់សច្ចាប័ន ឬការចូលជាសមាជិកដោយប្រទេសនានានៃសហភាព ការចូលជាធរមាន ]

១-

ក- ប្រទេសណាមួយនៃសហភាព ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ

អាចផ្តល់សច្ចាប័នបាន ហើយប្រសិនបើមិនបានចុះហត្ថលេខា អាចយល់ព្រមទទួលអនុសញ្ញានេះ។ លិខិតុបករណ៍នៃការផ្តល់សច្ចាប័ននិងការចូលជាសមាជិកត្រូវតម្កល់ជូនអគ្គនាយក។

ខ- ប្រទេសណាមួយនៃសហភាពអាចប្រកាសនៅក្នុងលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួន ថាការផ្តល់សច្ចាប័ន ឬការចូលជាសមាជិករបស់ខ្លួនមិនត្រូវអនុវត្តចំពោះ:

(i) មាត្រា១ ដល់ មាត្រា១២ ឬ

(ii) មាត្រា១៣ ដល់មាត្រា១៧។

គ- តាមអនុកថាខណ្ឌ(ខ)ខាងលើ ប្រទេសណាមួយនៃសហភាពដែលបានដកខ្លួនចេញពីអានុភាពនៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ក្រុមណាមួយនៃក្រុមមាត្រាទាំងពីរដូចមានចែងក្នុងអនុកថាខណ្ឌខាងលើ អាចប្រកាសទទួលយកអានុភាពនៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកទៅលើក្រុមមាត្រាទាំងនេះ នៅពេលក្រោយបាន។ សេចក្តីប្រកាសនេះត្រូវតម្កល់ជូនអគ្គនាយក។

២-

ក- មាត្រា១ ដល់មាត្រា១២ ត្រូវចូលជាធរមានចំពោះប្រទេសចំនួន១០(ដប់)ដំបូងនៃសហភាពដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយមិនបានធ្វើសេចក្តីប្រកាសក្រោមកថាខណ្ឌទី១(ខ)(i) ក្នុងរយៈពេលបីខែក្រោយពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកទី១០។

ខ- មាត្រា១៣ ដល់មាត្រា១៧ ត្រូវចូលជាធរមាន ចំពោះប្រទេសចំនួន១០(ដប់)ដំបូងនៃសហភាពដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដោយមិនបានធ្វើសេចក្តីប្រកាសក្រោមកថាខណ្ឌទី១(ខ)(ii) ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី១០។

គ- តាមបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ក)និង(ខ) លើកលែងការចូលជាធរមានដំបូងនៃក្រុមណាមួយនៃក្រុមមាត្រាទាំងពីរដូចមានចែងក្នុងកថាខណ្ឌទី១(ខ)(i)និង(ii) និងលើកលែងបទប្បញ្ញត្តិនៃកថាខណ្ឌទី១(ខ) ចំពោះប្រទេសណាមួយនៃសហភាព ក្រៅពីប្រទេសដែលមានចែងក្នុងអនុកថាខណ្ឌ(ក)និង(ខ) ដែលតម្កល់លិខិតុបរកណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ឬ ប្រទេសណាមួយនៃសហភាពដែលតម្កល់លិខិតុបរណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកតាមកថាខណ្ឌទី១(គ) មាត្រា១ដល់មាត្រា១៧ ត្រូវចូលជាធរមាន ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការ

តម្កល់នោះដោយអគ្គនាយក លើកលែងតែកាលបរិច្ឆេទបន្ទាប់មិនបានបង្ហាញនៅក្នុងលិខិតុបករណ៍ឬក្នុងសេចក្ដីប្រកាសដែលបានតម្កល់។ ករណីចុងក្រោយ ច្បាប់នេះត្រូវចូលជាធរមានចំពោះប្រទេសទាំងនោះ តាមកាលបរិច្ឆេទដែលបានកំណត់។

៣- ចំពោះប្រទេសណាមួយនៃសហភាពដែលបានតម្កល់លិខិតុបករណ៍នៃការផ្ដល់សច្ចាប័នឬការចូលជាសមាជិក មាត្រា១៨ដល់មាត្រា៣០ ត្រូវចូលជាធរមាននៅកាលបរិច្ឆេទដំបូង ដែលក្រុមណាមួយនៃក្រុមមាត្រាដូចមានចែងក្នុងកថាខណ្ឌទី១(ខ) ចូលជាធរមាន ចំពោះប្រទេសនោះអនុលោមតាមកថាខណ្ឌទី២(ក) (ខ)ឬ(គ)។

## មាត្រា២១

## [ ការចូលជាសមាជិកដោយប្រទេសក្រៅសហភាព ការចូលជាធរមាន ]

១- ប្រទេសក្រៅសហភាពណាមួយ អាចយល់ព្រមទទួលយកអនុសញ្ញានេះ ហើយក្លាយជាសមាជិកនៃសហភាព។ លិខិតុបករណ៍នៃការចូលជាសមាជិកត្រូវតម្កល់ជូនអគ្គ-នាយក។

២-

ក- ចំពោះប្រទេសណាមួយក្រៅសហភាព ដែលបានតម្កល់លិខិតុបករណ៍នៃការចូលជាសមាជិករបស់ខ្លួនក្នុងរយៈពេលមួយខែឬច្រើន មុនកាលបរិច្ឆេទនៃការចូលជាធរមាននៃបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះ អនុសញ្ញានេះត្រូវចូលជាធរមាន តាមកាលបរិច្ឆេទដែលបទប្បញ្ញត្តិដំបូងបានចូលជាធរមានតាមមាត្រា២០(២)(ក)ឬ(ខ) ប្រសិនបើកាលបរិច្ឆេទបន្ទាប់មិនបានបង្ហាញក្នុងលិខិតុបករណ៍នៃការចូលជាសមាជិក ឱ្យតែ:

(i) ប្រសិនបើ មាត្រា១ដល់មាត្រា១២ មិនចូលជាធរមានតាមកាលបរិច្ឆេទនោះទេ ប្រទេសនោះត្រូវជាប់កាតព្វកិច្ចតាមមាត្រា១ដល់មាត្រា១២នៃ ច្បាប់ លីស្បោន ក្នុងរយៈពេលបណ្ដោះអាសន្ន មុនការចូលជាធរមាននៃបទប្បញ្ញត្តិទាំងនេះ និងនៅពេលមានការជំនួស បទប្បញ្ញត្តិទាំងនេះ

(ii) ប្រសិនបើ មាត្រា១៣ដល់មាត្រា១៧ មិនបានចូលជាធរមានតាមកាលបរិច្ឆេទនោះទេ ប្រទេសនោះត្រូវជាប់កាតព្វកិច្ចតាមមាត្រា១៣ និង មាត្រា១៩(៣) (៤)និង(៥) នៃច្បាប់ លីស្បោន ក្នុងរយៈពេលបណ្ដោះអាសន្ន មុនការចូលជាធរមាននៃបទប្បញ្ញត្តិទាំងនេះ និងនៅពេលមានការជំនួសបទប្បញ្ញត្តិទាំងនេះ។

ប្រសិនបើប្រទេសមួយបានបង្ហាញកាលបរិច្ឆេទបន្ទាប់ នៅក្នុងលិខិតុបករណ៍នៃការ

ចូលជាសមាជិក ច្បាប់នេះត្រូវចូលជាធរមានចំពោះប្រទេសនេះតាមកាលបរិច្ឆេទដែលបានកំណត់។

ខ- ចំពោះប្រទេសណាមួយក្រៅសហភាពដែលបានតម្កល់លិខិតុបករណ៍នៃការចូលជាសមាជិក តាមកាលបរិច្ឆេទបន្ទាប់ពីការចូលជាធរមាននៃក្រុមមាត្រានៃច្បាប់នេះ ឬតាមកាលបរិច្ឆេទតិចជាង១(មួយ)ខែមុនការចូលជាធរមាននេះ លើកលែងចំពោះបទប្បញ្ញត្តិនៃអនុកថាខណ្ឌ(ក) ច្បាប់នេះត្រូវចូលជាធរមាន៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការចូលជាសមាជិកដោយអគ្គនាយក លើកលែងតែកាលបរិច្ឆេទបន្ទាប់បានបង្ហាញនៅក្នុងលិខិតុបករណ៍នៃការចូលជាសមាជិក។ ករណីចុងក្រោយ ច្បាប់នេះត្រូវចូលជាធរមានចំពោះប្រទេសទាំងនោះ តាមកាលបរិច្ឆេទដែលបានកំណត់។

៣- ចំពោះប្រទេសណាមួយក្រៅសហភាព ដែលបានតម្កល់លិខិតុបករណ៍នៃការចូលជាសមាជិក ក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃច្បាប់នេះទាំងមូល ឬតិចជាងមួយខែមុនកាលបរិច្ឆេទនេះ ច្បាប់នេះត្រូវចូលជាធរមាន៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការចូលជាសមាជិកដោយអគ្គនាយក លើកលែងតែកាលបរិច្ឆេទបន្ទាប់បានបង្ហាញនៅក្នុងលិខិតុបករណ៍នៃការចូលជាសមាជិក។ ករណីចុងក្រោយ ច្បាប់នេះត្រូវចូលជាធរមានចំពោះប្រទេសទាំងនោះ តាមកាលបរិច្ឆេទដែលបានកំណត់។

## មាត្រា២២

## [ វិបាកនៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ]

លើកលែងតែអញ្ញត្រកម្មដូចមានចែងក្នុងមាត្រា២០(១)(ខ) និងមាត្រា២៨(២) ការផ្តល់សច្ចាប័នឬការចូលជាសមាជិក ត្រូវទទួលយកជាស្វ័យប្រវត្តិនូវរាល់ខចែង និងការទទួលបានផលប្រយោជន៍ទាំងឡាយ ក្នុងច្បាប់នេះ។

## មាត្រា២៣

## [ ការចូលជាសមាជិកក្នុងច្បាប់មុនៗ ]

បន្ទាប់ពីច្បាប់នេះចូលជាធរមានទាំងមូល ប្រទេសណាមួយមិនអាចបដិសេធច្បាប់មុនៗនៃអនុសញ្ញានេះបានទេ។

## មាត្រា២៤

## [ ដែនដី ]

១- ប្រទេសណាមួយអាចប្រកាស ក្នុងលិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ឬអាចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយកពេលណាក៏បាន ថាអនុសញ្ញានេះអាចអនុវត្តបានចំពោះដែនដីទាំងមូលឬផ្នែកណាមួយនៃដែនដីទាំងនេះ ដូចដែលបានកំណត់ក្នុងសេចក្តីប្រកាសឬសេចក្តីជូនដំណឹង ដើម្បីឱ្យប្រទេសនេះទំនួលខុសត្រូវ

ចំពោះទំនាក់ទំនងខាងក្រៅ។

២- ប្រទេសណាមួយដែលបានប្រកាស ឬបានជូនដំណឹងដូចខាងលើ អាចជូនដំណឹងទៅអគ្គនាយកពេលណាក៏បាន ថាអនុសញ្ញានេះមិនអាចអនុវត្តបានតទៅទៀតចំពោះដែនដីទាំងមូលឬផ្នែកណាមួយនៃដែនដីទាំងនេះ។

៣-

ក- សេចក្តីប្រកាសណាមួយដែលធ្វើឡើងក្រោមកថាខណ្ឌ១ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទដូចកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នឬការចូលជាសមាជិកដូចមានចែងក្នុងលិខិតុបករណ៍។ សេចក្តីជូនដំណឹងណាមួយដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវចូលជាធរមាន៣ (បី)ខែបន្ទាប់ពីការជូនដំណឹងដោយអគ្គនាយក។

ខ- សេចក្តីជូនដំណឹងដែលបានធ្វើតាមកថាខណ្ឌ២ ត្រូវចូលជាធរមាន១២ (ដប់ពីរ)ខែបន្ទាប់ពីអគ្គនាយកទទួលបានសេចក្តីជូនដំណឹងនេះ។

## មាត្រា២៥

## [ ការអនុវត្តន៍អនុសញ្ញានៅថ្នាក់ជាតិ ]

១- ប្រទេសណាមួយជាភាគីនៃអនុសញ្ញានេះ ត្រូវអនុម័តវិធានការចាំបាច់ដើម្បីធានាការអនុវត្តអនុសញ្ញានេះ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសខ្លួន។

២- នៅពេលដែលប្រទេសមួយតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នឬការចូលជាសមាជិក ច្បាប់ជាតិជាអ្នកផ្តល់អានុភាពអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

## មាត្រា២៦

## [ ការប្រកាសដកខ្លួនចេញ ]

១- អនុសញ្ញានេះមានអានុភាពរហូត ដោយមិនកំណត់ពេលវេលា។

២- ប្រទេសណាមួយអាចប្រកាសដកខ្លួនចេញពីច្បាប់នេះ ដោយជូនដំណឹងទៅអគ្គនាយក។ ការប្រកាសដកខ្លួនចេញនេះត្រូវចាត់ទុកជាការដកខ្លួនចេញពីច្បាប់មុនៗទាំងអស់ ហើយប៉ះពាល់ចំពោះតែប្រទេសដែលបានប្រកាសដកខ្លួនតែប៉ុណ្ណោះ។អនុសញ្ញានេះនៅតែអនុវត្តបាន និងមានអានុភាពចំពោះប្រទេសផ្សេងទៀតនៃសហភាព។

៣- ការប្រកាសដកខ្លួនចេញ ត្រូវមានអានុភាពក្នុងរយៈពេល១(មួយ)ឆ្នាំក្រោយថ្ងៃដែលអគ្គនាយកបានទទួលសេចក្តីជូនដំណឹង។

៤- សិទ្ធិប្រកាសដកខ្លួនចេញដែលបានចែងក្នុងមាត្រានេះ អាចអនុវត្តចំពោះប្រទេសណាមួយបាន តែក្រោយផុតរយៈពេល៥(ប្រាំ)ឆ្នាំ ដោយរាប់ចាប់ពីកាលបរិច្ឆេទដែលប្រទេសនេះក្លាយជាសមាជិកសហភាព។

## មាត្រា២៧

### [ ការអនុវត្តន៍ច្បាប់មុនៗ ]

១- ចំពោះទំនាក់ទំនងរវាងប្រទេសទាំងឡាយ ដែលត្រូវអនុវត្តច្បាប់នេះនិងកម្រិតដែលត្រូវអនុវត្ត ច្បាប់នេះ ត្រូវជំនួសអនុសញ្ញាទីក្រុងប៉ារីស ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ និងច្បាប់កែប្រែបន្តបន្ទាប់។

២-

ក- ចំពោះប្រទេសទាំងឡាយ ដែលច្បាប់នេះមិនអនុវត្ត ឬ មិនអនុវត្តទាំងស្រុង ប៉ុន្តែអនុវត្ត ច្បាប់ លីស្បោន ចុះថ្ងៃទី៣១ខែតុលាឆ្នាំ១៩៥៨ ច្បាប់ក្រោយនេះត្រូវនៅមានអានុភាពអនុវត្តទាំងស្រុង ឬ ត្រឹមកម្រិតដែលច្បាប់បច្ចុប្បន្នមិនបានជំនួសដូចមានចែងក្នុងកថាខណ្ឌទី១។

ខ- ដូចគ្នានេះដែរ ចំពោះប្រទេសទាំងឡាយ ដែលមិនអនុវត្តច្បាប់បច្ចុប្បន្ននេះឬផ្នែកណាមួយនៃច្បាប់នេះឬច្បាប់លីស្បោន ច្បាប់ទីក្រុងឡុង ចុះថ្ងៃទី២ខែមិថុនាឆ្នាំ១៩៣៤ ត្រូវនៅមានអានុភាពអនុវត្តទាំងស្រុង ឬត្រឹមកម្រិតដែលច្បាប់នេះមិនបានជំនួស ដូចមានចែងក្នុងកថាខណ្ឌទី១។

គ- ដូចគ្នានេះដែរ ចំពោះប្រទេសទាំងឡាយ ដែលមិនអនុវត្តច្បាប់នេះ ឬផ្នែកណាមួយនៃច្បាប់នេះឬច្បាប់លីស្បោនឬច្បាប់ទីក្រុងឡុង ច្បាប់ទីក្រុងឡាអេ ចុះថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ១៩២៥ ត្រូវនៅមានអានុភាពអនុវត្តទាំងស្រុង ឬ ត្រឹមកម្រិតដែលច្បាប់នេះមិនបានជំនួស ដូចមានចែងក្នុងកថាខណ្ឌទី១។

៣- ប្រទេសក្រៅសហភាពទាំងឡាយ ដែលក្លាយជាភាគីនៃច្បាប់នេះ ត្រូវអនុវត្តច្បាប់នេះចំពោះប្រទេសណាមួយនៃសហភាព ដែលមិនមែនជាភាគីនៃច្បាប់នេះ ឬ ជាភាគីនៃច្បាប់នេះ តែបានធ្វើសេចក្តីប្រកាសតាមមាត្រា២០(១)(ខ)(i) ។ ប្រទេសទាំងនេះទទួលស្គាល់ថាប្រទេសនៃសហភាព ដែលបានលើកឡើងនេះ អាចអនុវត្តបទប្បញ្ញត្តិនៃច្បាប់ថ្មីបំផុតដែលខ្លួនជាភាគី ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសទាំងនេះ។

## មាត្រា២៨

### [ ជម្លោះ]

១- ជម្លោះរវាងប្រទេសពីរ ឬច្រើននៃសហភាពចំពោះការបកស្រាយឬការអនុវត្តន៍អនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានដោយការចរចារ អាចយកទៅប្តឹង ដោយប្រទេសណាមួយដែលពាក់ព័ន្ធនៃសហភាព ទៅតុលាការយុត្តិធម៌អន្តរជាតិ ដោយអនុលោមតាមលក្ខន្តិកៈនៃតុលាការ លើកលែងតែប្រទេសពាក់ព័ន្ធទាំងនេះយល់ព្រមលើ

វិធីដោះស្រាយផ្សេងទៀត។ ប្រទេសដែលប្ដឹងទៅតុលាការនេះ ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ។ ការិយាល័យអន្តរជាតិ ត្រូវជូនដំណឹងទៅប្រទេសផ្សេងទៀតនៃសហភាពអំពីរឿងនេះ។

២- នៅពេលចុះហត្ថលេខាលើច្បាប់នេះឬតម្កល់លិខិតុបករណ៍នៃការផ្ដល់សច្ចាប័ន ឬការចូលជាសមាជិក ប្រទេសនីមួយៗអាចប្រកាសថាខ្លួន មិនជាប់កាតព្វកិច្ចទៅនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១។ ចំពោះជំលោះកើតឡើងរវាងប្រទេសនេះនិងប្រទេសដទៃទៀតនៃសហភាព បទប្បញ្ញត្តិនៃកថាខណ្ឌទី១ មិនត្រូវអនុវត្តទេ។

៣- ប្រទេសណាមួយ ដែលបានធ្វើសេចក្ដីប្រកាស ដូចមានចែងក្នុងបទប្បញ្ញត្តិនៃកថាខណ្ឌទី២ អាចដកសេចក្ដីប្រកាសវិញនៅពេលណាក៏បាន ដោយជូនដំណឹងទៅអគ្គនាយក។

## មាត្រា២៩

## [ការចុះហត្ថលេខា ភាសា មុខងារនៃការតម្កល់]

១-

ក- ច្បាប់នេះត្រូវចុះហត្ថលេខាជាឯកសារតែមួយ ជាភាសាបារាំង និងត្រូវតម្កល់ជូនរដ្ឋាភិបាលនៃប្រទេសស៊ុយអ៊ែត។

ខ- អត្ថបទផ្លូវការត្រូវធ្វើឡើងដោយអគ្គនាយក បន្ទាប់ពីពិភាក្សាជាមួយនឹងរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាភាសា អង់គ្លេស អាឡឺម៉ង់ អ៊ីតាលី ព័រទុយហ្គាល់ រុស្ស៊ី អេស្ប៉ាញ និងភាសាផ្សេងទៀត ដែលសន្និបាតកំណត់។

គ- ករណីមានយោបល់ខុសគ្នា លើការបកប្រែអត្ថបទផ្សេងៗ អត្ថបទជាភាសាបារាំងត្រូវយកជាគោល។

២- ច្បាប់នេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខា នៅទីក្រុង ស្តុកហូម រហូតដល់ ថ្ងៃទី១៣ខែមករា ឆ្នាំ១៩៦៨។

៣- អគ្គនាយកត្រូវបញ្ជូនច្បាប់ចម្លង២(ពីរ)ច្បាប់នៃអត្ថបទដែលបានចុះហត្ថលេខានៃអនុសញ្ញានេះ ដែលបញ្ជាក់ថាត្រឹមត្រូវដោយរដ្ឋាភិបាលប្រទេសស៊ុយអ៊ែត ទៅរដ្ឋាភិបាលនៃប្រទេសទាំងអស់ក្នុងសហភាព និងទៅប្រទេសផ្សេងទៀតតាមការស្នើសុំ។

៤- អគ្គនាយកត្រូវចុះបញ្ជីច្បាប់នេះនៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

៥- អគ្គនាយកត្រូវជូនដំណឹងដល់រដ្ឋាភិបាលនៃប្រទេសទាំងអស់នៃសហភាពអំពីការចុះហត្ថលេខា ការតម្កល់លិខិតុបករណ៍នៃការផ្ដល់សច្ចាប័នឬការចូលជាសមាជិកនិងសេចក្ដីប្រកាសណាមួយដែលមានភ្ជាប់ទៅក្នុងលិខិតុបករណ៍ទាំងនោះ ឬ សេចក្ដីប្រកាស

ដែលធ្វើឡើងដូចមានចែងក្នុងមាត្រា២០(១)(គ) ការចូលជាធរមាននៃបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ សេចក្តីជូនដំណឹងនៃការប្រកាសដកខ្លួនចេញ និង សេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា២៩។

## មាត្រា៣០

## [អន្តរប្បញ្ញត្តិ]

១- រហូតដល់ពេលអគ្គនាយកដំបូងចូលកាន់ដំណែង ការយោងក្នុងច្បាប់នេះដល់ការិយាល័យអន្តរជាតិនៃអង្គការ ឬដល់អគ្គនាយក ត្រូវចាត់ទុកថាជាការយោងដល់ការិយាល័យនៃសហភាព ឬនាយកការិយាល័យ តាមករណីនីមួយៗ។

២- ៥(ប្រាំ)ឆ្នាំបន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញា ស្តីពីការបង្កើតអង្គការប្រទេសទាំងឡាយនៃសហភាពដែលមិនជាប់កាតព្វកិច្ចតាមមាត្រា១៣ ដល់មាត្រា១៧ បើចង់ អាចអនុវត្តសិទ្ធិដូចមានចែងនៅក្នុងមាត្រា១៣ដល់មាត្រា១៧នៃច្បាប់នេះ ហាក់បីដូចជាប្រទេសទាំងនេះជាប់កាតព្វកិច្ចតាមមាត្រាទាំងនេះដែរ។ ប្រទេសណាមួយដែលចង់អនុវត្តសិទ្ធិនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយក។ ការជូនដំណឹងនេះត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការទទួល។ ប្រទេសទាំងនេះត្រូវចាត់ទុកជាសមាជិកសន្និបាត រហូតដល់ពេលផុតកំណត់នៃរយៈពេលនេះ។

៣- នៅពេលដែលប្រទេសទាំងឡាយនៃសហភាព មិនទាន់ក្លាយជាសមាជិកនៃអង្គការ ការិយាល័យអន្តរជាតិនៃអង្គការ ត្រូវដើរតួជាការិយាល័យនៃសហភាព ហើយអគ្គនាយក ជានាយកនៃការិយាល័យផងដែរ។

៤- នៅពេលដែលប្រទេសទាំងឡាយនៃសហភាព បានក្លាយជាសមាជិកនៃអង្គការ សិទ្ធិ កាតព្វកិច្ច និងទ្រព្យសម្បត្តិនៃការិយាល័យនៃសហភាព ត្រូវប្រគល់ឱ្យការិយាល័យអន្តរជាតិនៃអង្គការ។